World Vision



# របាយការណ៍ប្រចាំឆ្នាំ ២០២៣

## កម្ពុជា


SPORT
NIKE

World Vision

អង្គការទស្សនៈពិភពលោក គឺជាអង្គការមនុស្សធម៌ផ្នែកជំនួយសង្គ្រោះ អភិវឌ្ឍ និងតស៊ូមតិ បែបគ្រិស្តសាសនា ដែលធ្វើការជាមួយកុមារ គ្រួសារ និងសហគមន៍ ដើម្បីជម្នះភាពក្រីក្រ និងអយុត្តិធម៌។ ដោយដើរតាមគុណតម្លៃជាគ្រិស្តបរិស័ទ យើងផ្តោតសំខាន់លើការធ្វើការជាមួយក្រុមជនងាយរងគ្រោះនៅទូទាំងពិភពលោក ដោយមិនរើសអើងសាសនា វណ្ណៈ យេនឌ័រ ឬជាតិសាសន៍។

# ចក្ខុវិស័យ

## របស់យើង

- **ចក្ខុវិស័យរបស់យើង** គឺកុមារគ្រប់រូបរស់នៅក្នុងជីវិតដែលពេញបរិបូណ៌។
- **យើងអធិស្ឋាន**សម្រាប់មនុស្សគ្រប់រូប និងមានឆន្ទៈក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យរបស់យើង។

# គុណតម្លៃ

## របស់យើង

- យើងជាគ្រិស្តបរិស័ទ
- យើងប្តេជ្ញាចិត្តជួយជនក្រីក្រ
- យើងគោរពតម្លៃមនុស្ស
- យើងជាអ្នកបម្រើដែលមានការទទួលខុសត្រូវខ្ពស់
- យើងជាដៃគូ
- យើងជាអ្នកឆ្លើយតប

# មាតិកា


០១ ផែនទីបង្ហាញផ្លូវយុទ្ធសាស្ត្រ ឆ្នាំ ២០២៣ - ២០២៧

០៨ បុព្វកថា

១០ សារពីនាយកប្រតិបត្តិ

១២ តំបន់គោលដៅរបស់យើង

១៣ សមិទ្ធផលរបស់យើង

១៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

១៥ កម្មវិធីសុខភាព និងអាហារូបត្ថម្ភ

១៩ កម្មវិធីទឹកស្អាត និងអនាម័យ (WASH)

២៣ ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍសហគ្រាស

២៧ កម្មវិធីកិច្ចការពារ និងការចូលរួមរបស់កុមារ

៣១ ការអប់រំបរិយាបន្ន

៣៥ គណនេយ្យភាពសង្គម

៣៩ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះមហន្តរាយ

៤៣ សមភាពយេនឌ័រ ពិការភាព និង បរិយាបន្នសង្គម (GEDSI)

៤៥ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

៤៧ ការតស៊ូមតិ និងយុទ្ធនាការ

៤៩ ដៃគូរបស់យើង

៥១ ដៃគូអភិវឌ្ឍន៍

៥២ របាយការណ៍ហិរញ្ញវត្ថុ

៥៤ រឿងនៃការផ្លាស់ប្តូរ

# ផែនទីយុទ្ធសាស្ត្រ

## អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា

ឆ្នាំ២០២៣ - ២០២៧

កុមារា និងកុមារី៥លាននាក់

**គោលដៅយុទ្ធសាស្ត្រ៖ សម្រេចបាននូវសុខុមាលភាពសម្រាប់កុមារា និងកុមារី ៥លាននាក់ ពិសេសកុមារដែលងាយរងគ្រោះបំផុត**

** គោលបំណងយុទ្ធសាស្ត្រ*

## ផលវិជ្ជមាននៃកម្មវិធី

### គោលបំណងយុទ្ធសាស្ត្រទី ១

បង្កើនចំនួនកុមារ និងក្មេងវ័យជំទង់ ដែលទទួលបានការការពារពីគ្រប់ទម្រង់ នៃអំពើហិង្សា និងអាចចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្ត

### គោលបំណងយុទ្ធសាស្ត្រទី ២

បង្កើនចំនួនកុមារដែលមានសុខភាពល្អ ទទួលបានអាហារូបត្ថម្ភត្រឹមត្រូវ ទឹកស្អាត អនាម័យ និងរស់នៅជាមួយគ្រួសារដែលមានស្ថិរភាពហិរញ្ញវត្ថុ

### គោលបំណងយុទ្ធសាស្ត្រទី ៣

បង្កើនចំនួនកុមារដែលចេះអាន និងសរសេរសម្រាប់ជីវិតរបស់ពួកគេ

**ពង្រឹងបន្ថែម និងបញ្ចូលនូវកម្មវិធីអន្តរវិស័យទាំង ៥**

ក. ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

ខ. សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

គ. ការពង្រឹងប្រព័ន្ធច្បាប់ និងការជះឥទ្ធិពលទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល

ឃ. ការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម

ង. ការចូលរួមរបស់កុមារ និងយុវជន

## មូលនិធិកម្មវិធី

### គោលបំណងយុទ្ធសាស្ត្រទី ៤

ពិពិធកម្មប្រភពមូលនិធិ

### គោលបំណងយុទ្ធសាស្ត្រទី ៥

ត្រៀមលក្ខណៈជាមុនសម្រាប់ការធ្វើអង្គាសក្នុងស្រុក

**ORGANISATIONAL PROCCESS EXCELLENCE**

### គោលបំណងយុទ្ធសាស្ត្រទី ៦

បង្កើនប្រសិទ្ធភាពនៃប្រព័ន្ធប្រតិបត្តិការតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល

### គោលបំណងយុទ្ធសាស្ត្រទី ៧

ពង្រឹងភាពជាដៃគូជាមួយអង្គការក្នុងស្រុក

### គោលបំណងយុទ្ធសាស្ត្រទី ៨

ពង្រឹងប្រព័ន្ធតាមដាន ការស្រាវជ្រាវ និងការបោះពុម្ពដែលផ្ដោតលើមជ្ឈដ្ឋានខាងក្រៅ និងអភិក្រមកម្មវិធីនវានុវត្តន៍

## ការអភិវឌ្ឍបុគ្គលិក

### គោលបំណងយុទ្ធសាស្ត្រទី ៩

លើកស្ទួយវប្បធម៌បើកចំហ និងភាពជាអ្នកដឹកនាំដែលបម្រើក្នុងស្ថាប័ន ដែលជាការឆ្លុះបញ្ចាំងអំពីគុណតម្លៃរបស់អង្គការទស្សនៈពិភពលោក និងអត្តសញ្ញាណជាគ្រិស្តបរិស័ទ

### គោលបំណងយុទ្ធសាស្ត្រទី ១០

ជ្រើសរើស និងរក្សាក្រុមដែលមានទេពកោសល្យ និងប្រសិទ្ធភាពការងារខ្ពស់

## ▶ វិស័យ បច្ចេកទេស

- កម្មវិធីសុខភាព និង អាហារូបត្ថម្ភ
- កម្មវិធីទឹកស្អាត និង អនាម័យ
- ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព និង ការអភិវឌ្ឍសហគ្រាស
- កម្មវិធីកិច្ចការពារ និងការចូលរួមរបស់កុមារ
- ការអប់រំបរិយាបន្ន

## ▶ វិធីសាស្ត្រដែលមានលក្ខណៈអន្តរវិស័យ

- គណនេយ្យភាពសង្គម
- ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះមហន្តរាយ
- សមភាពយេនឌ័រ ពិការភាព និង បរិយាបន្នសង្គម (GEDSI)
- ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ

# បុព្វកថា



ខ្ញុំបាទពិតជាមានក្តីសោមនស្ស សូមផ្សព្វផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជាដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់យើងក្នុងការនាំមកនូវការផ្លាស់ប្តូរដ៏សំខាន់ក្នុងជីវិតរបស់កុមារ និងសហគមន៍ដែលងាយរងគ្រោះបំផុតនៅទូទាំងប្រទេស។ បេសកកម្មរបស់អង្គការទស្សនៈពិភពលោកក្នុងការបម្រើដល់មនុស្សគ្រប់រូបដោយមិនគិតពីប្រវត្តិ ឬទីតាំងដែលគាត់រស់នៅ ជាពិសេសក្នុងស្ថានភាពដ៏លំបាកបំផុត គឺនៅតែស្ថិតក្នុងចំណុចស្នូលនៃការងាររបស់យើង។

រយៈពេលមួយឆ្នាំកន្លងទៅនេះ អង្គការទស្សនៈពិភពលោក បានធ្វើការបោះជំហានយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខុមាភាពកុមារ ដោយផ្តោតសំខាន់លើការធ្វើឱ្យជីវិតកុមារប្រសើរឡើង ក៏ដូចជាការបណ្តុះនូវគុណតម្លៃវិជ្ជមានតាមរយៈរាល់សកម្មភាពអន្តរាគមន៍របស់យើង។ ក្នុងចន្លោះឆ្នាំ ២០២២ និង២០២៣ កុមារជាង ១,៥ លាននាក់នៅក្នុងប្រទេសកម្ពុជាបានទទួលផលជាវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលពីគំនិតផ្តួចផ្តើមពហុវិស័យរបស់អង្គការទស្សនៈពិភពលោក។ យើងបានធ្វើការជាមួយកុមារ យុវជន អង្គការសហគមន៍មូលដ្ឋាន រាជរដ្ឋាភិបាល/អាជ្ញាធរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក្រុមជំនឿ និងដៃគូអភិវឌ្ឍន៍ ដែលបានពង្រឹងបន្ថែមនូវការប្តេជ្ញាចិត្តរបស់យើងដើម្បីលើកកម្ពស់សុខុមាលភាពកុមារតាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការ។

វិធីសាស្ត្ររបស់អង្គការទស្សនៈពិភពលោក គឺសំដៅលើការផ្តល់សិទ្ធិអំណាចដល់សហគមន៍ដើម្បីដោះស្រាយនូវឫសគល់នៃភាពក្រីក្រ ហើយយុទ្ធសាស្ត្រសុខុមាលភាពកុមាររបស់យើង មានគោលបំណងផ្តល់ផលជាវិជ្ជមានដល់កុមារី និងកុមារា ជាង៥លាននាក់ក្នុងប្រទេសកម្ពុជានាឆ្នាំ២០២៧។ គោលបំណងសំខាន់ៗនោះរួមមាន ការជំរុញឱ្យមានទំនាក់ទំនងវិជ្ជមាន និងសន្តិភាពក្នុងគ្រួសារនិងសហគមន៍ ពង្រឹងកិច្ចការពារពីអំពើហិង្សា កែលម្អស្ថានភាពអាហារូបត្ថម្ភឱ្យបានប្រសើរឡើង បង្កើនអត្រាអក្ខរកម្មក្នុងចំណោមកុមារនៅក្នុងថ្នាក់បឋមសិក្សា លើកកម្ពស់ភាពធន់ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាការកែលម្អការអប់រំ សុខភាព និងការផ្តល់សេវារដ្ឋបាលថ្នាក់ឃុំ តាមរយៈការសម្របសម្រួលកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការផ្សេងៗជាមួយអ្នកផ្តល់សេវា និងប្រជាពលរដ្ឋ។

របាយការណ៍នេះបានបង្ហាញពីរឿងនៃការផ្លាស់ប្តូរជាច្រើន ក៏ដូចជារំលេចឱ្យឃើញនូវសមិទ្ធផលដែលបានកើតឡើងនៅតាមសហគមន៍ តាមរយៈកិច្ចសហការណ៍ដ៏រឹងមាំ និងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ និងការផ្តល់មូលនិធិសប្បុរសពីអ្នកគាំទ្រ និងដៃគូអភិវឌ្ឍន៍របស់អង្គការទស្សនៈពិភពលោក។ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរបស់អង្គការទស្សនៈពិភពលោកជាមួយដៃគូ ភាគីពាក់ព័ន្ធ និងសហគមន៍ក្នុងឆ្នាំ ២០២៣ មានកុមារខ្វះអាហារូបត្ថម្ភជាង ១ ២៦៣ នាក់ត្រូវបានរកឃើញ និងទទួលបានការគាំទ្រនៅផ្ទះ ឬបញ្ជូនទៅមណ្ឌលសុខភាពក្បែរខ្លួន។ ប្រជាជនជាង ៧៨ ៣៩៥ នាក់បានទទួលទឹកស្អាតប្រើប្រាស់។ ឃុំចំនួន ៤៧ឃុំបានប្រកាសថាបានបញ្ឈប់ទាំងស្រុងនូវការបន្ទោបង់ពាសវាលពាសកាល។ សហគមន៍កសិកម្មចំនួន ២៨សហគមន៍ ដែលមានសមាជិកចំនួន ៤០៤០ នាក់ ត្រូវបានពង្រឹង ហើយឥឡូវនេះកំពុងគ្រប់គ្រងមូលធនដែលមានទឹកប្រាក់សរុបចំនួន ១ ២៧៤ ៣៧៧ ដុល្លារអាមេរិក និងបានវិនិយោគទឹកប្រាក់ចំនួន ៦ ៥០០ដុល្លារអាមេរិក ត្រឡប់ទៅសហគមន៍របស់ពួកគេវិញតាម រយៈមូលនិធិសង្គម។ សហគ្រាសធនតូច និងមធ្យមចំនួន ១៨៧ បានទទួលប្រាក់កម្ចីសរុបចំនួន ៥ ២៥៨ ០៨៤ដុល្លារអាមេរិក ដើម្បីពង្រីកនូវអាជីវកម្មរបស់ពួកគេ។ ៨៧% នៃឃុំគោលដៅនៃអង្គការទស្សនៈពិភពលោក បានបែងចែកថវិកាផ្ទាល់ខ្លួន ដើម្បីពង្រឹងនូវយន្តការកិច្ចការពារកុមារនៅក្នុងតំបន់របស់ពួកគេ។ សាលារៀនចំនួន ៧៨សាលា បានផ្លាស់ប្តូរការអនុវត្តរបស់ពួកគេដោយរួមបញ្ចូលនូវការប្រជុំទៀងទាត់ជាមួយឪពុកម្តាយរបស់សិស្សដែលរៀនយឺត ដើម្បីធ្វើផែនការគាំទ្ររួមគ្នា។ ប្រជាជនដែលបានរងផលប៉ះពាល់ដោយគ្រោះមហន្តរាយចំនួន ២ ១៥០ គ្រួសារ ដោយរួមបញ្ចូលទាំងកុមារចំនួន ៤ ៣៤៥ នាក់ ត្រូវទទួលបានជំនួយសង្គ្រោះពីការឆ្លើយតបនឹងគ្រោះទឹកជំនន់របស់អង្គការទស្សនៈពិភពលោក។ លើសពីនេះទៀត ជាលទ្ធផលនៃការអនុវត្តប្រព័ន្ធគណនេយ្យភាពសង្គម មានរដ្ឋបាលឃុំ សង្កាត់ចំនួន ៤៧០ មណ្ឌលសុខភាពចំនួន ៣៧៩ និងសាលាបឋមសិក្សាចំនួន ២ ០៨៨ ដែលប្រើប្រាស់ដោយប្រជាពលរដ្ឋជាង ៣,៧ លាននាក់ បានធ្វើការពង្រឹងនូវការផ្តល់សេវាកម្មរបស់ពួកគេ។



ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះបុគ្គលិកអង្គការទស្សនៈពិភពលោកទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដៃគូ ម្ចាស់ជំនួយ អ្នកឧបត្ថម្ភ និងរាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើកិច្ចការទាំងអស់នេះទៅរួច។ យើងទាំងអស់គ្នាត្រូវរួបរួមគ្នា ជាកម្លាំងនិងឆ្លុងមួយសម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាន ធានាបាននូវអនាគតភ្លឺស្វាង និងប្រកបដោយបរិយាបន្នសម្រាប់កុមារ និងសហគមន៍ទាំងអស់ក្នុងប្រទេសកម្ពុជា។

សូមអរគុណច្រើន!

**ជេនេស អ៊ីម៉ានូអ៊ែល ហ្គីនទីញ**
នាយកប្រចាំប្រទេស

# សារពីនាយកប្រតិបត្តិ

## ក្នុងដំណើរទស្សនកិច្ចរបស់លោកនៅប្រទេសកម្ពុជា

### ការយល់ឃើញរបស់នាយកប្រតិបត្តិ៖ ដំណើរនៃក្តីសង្ឃឹម និងការផ្លាស់ប្តូរ

ក្នុងអំឡុងពេលដែលខ្ញុំបានទៅទស្សនៈកិច្ចស្រុកគូលែន ដែលស្ថិតនៅភូមិភាគខាងជើងនៃប្រទេសកម្ពុជាថ្មីៗនេះ ខ្ញុំបានជួបប្រទះនឹងបញ្ហា ក៏ដូចជារឿងរ៉ាវដែលបានឆ្លុះបញ្ចាំងពីការតស៊ូ និងក្តីសង្ឃឹម។ បទពិសោធន៍ដែលបានចែករំលែក និងចំណាប់អារម្មណ៍ក្នុងដំណើរទស្សនកិច្ចនេះ បានបន្សល់ទុកនូវការចងចាំដែលមិនអាចបំភ្លេចបាន ដោយបានជះឥទ្ធិពលលើការយល់ឃើញរបស់ខ្ញុំមកលើការងាររបស់យើង ហើយក៏បានសបញ្ជាក់ពីសារៈសំខាន់នៃបេសកកម្មរបស់យើង។

អ្វីដែលបានដក់ជាប់ក្នុងចិត្តខ្ញុំនោះ គឺការសន្ទនារបស់ខ្ញុំជាមួយនឹងម៉ូនិចដែល ជាយុវតីអាយុ ១៦ ឆ្នាំដែលរស់នៅក្នុងភូមិ ។ រឿងដែលម៉ូនិចបានរៀបរាប់មកយើង បង្ហាញយ៉ាងច្បាស់ពីការផ្លាស់ប្តូរដ៏សំខាន់តាមរយៈសកម្មភាពអន្តរាគមន៍របស់អង្គការទស្សនៈពិភពលោក។ នាងបានរៀបរាប់ពីដំណើរដ៏នឿយហត់ដែលនាងត្រូវឆ្លងកាត់ពីរដងក្នុងមួយថ្ងៃដើម្បីទៅដងយកទឹកមកប្រើប្រាស់ ដែលនេះធ្វើឱ្យនាងចំណាយពេលវេលា និងប៉ះពាល់ដល់សុខភាព និងការរៀនសូត្ររបស់នាង។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមរបស់អង្គការទស្សនៈពិភពលោក និងសហគមន៍មូលដ្ឋាន គម្រោងការបញ្ចៀបទឹក ក៏ត្រូវបានអនុវត្តហើយបាននាំមកនូវការផ្លាស់ប្តូរយ៉ាងសំខាន់ក្នុងជីវិតរបស់យុវតីមួយរូបនេះ។ ដោយលែងមាននូវបន្ទុកក្នុងការស្វែងរកទឹកមកប្រើប្រាស់ទៀត ម៉ូនិចអាចផ្តោតលើការសិក្សារបស់នាងដោយមិនមានភាពភ័យខ្លាចថានឹងឆ្លងនូវជំងឺផ្សេងៗ។ ដំណើររឿងរបស់ម៉ូនិចបានតំណាងឱ្យការផ្តល់នូវសិទ្ធិអំណាច សេចក្តីថ្លៃថ្នូរ និងការផ្តល់ឱកាស ហើយក៏បានឆ្លុះបង្ហាញពីការផ្តល់នូវផលជាវិជ្ជមានដ៏ស្ថិតស្ថេរតាមរយៈការងាររបស់យើង។




នៅពេលដែលខ្ញុំបានធ្វើដំណើរឆ្លងកាត់ភូមិគូលែន ខ្ញុំក៏មានឱកាស

ដ៏វិសេសវិសាលដោយបានចូលរួមជាមួយក្រុមការងារដែលមានឆន្ទៈខ្ពស់របស់យើង ដឹកនាំដោយលោក ជេនេស ហ្គីនទីញ ដែលជានាយកប្រចាំប្រទេសកម្ពុជា។ ការយល់ដឹងរបស់លោកបានសបញ្ជាក់ពីធម្មជាតិនៃការងាររបស់យើងដែលមានលក្ខណៈចម្រុះដោយរួមបញ្ចូលទាំងពីការដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភ រហូតដល់ការលុបបំបាត់អំពើហិង្សាលើកុមារ។ ស្ថិតិដ៏គួរឱ្យភ្ញាក់ផ្អើលមួយ បានបង្ហាញពីអត្រាប្រេវ៉ាឡង់ចំនួន ២២% នៃបញ្ហាក្រិសក្រិនក្នុងចំណោមកុមារ ដែលនេះជាការរំលឹកដ៏ចាំបាច់ពីបញ្ហាដែលយើងត្រូវប្រឈមមុខ។ ប៉ុន្តែទន្ទឹមនឹងបញ្ហាប្រឈមទាំងនេះ ខ្ញុំក៏បានសង្កេតឃើញនូវសមិទ្ធផលដោយផ្ទាល់ចេញពីកម្មវិធីរបស់យើង ដូចជាគំនិតផ្តួចផ្តើម (Positive Deviance Hearth Initiative) ដែលបានផ្តល់សិទ្ធិអំណាចដល់ម្តាយវ័យក្មេងក្នុងការផ្តល់នូវអាហារដែលមានអាហារូបត្ថម្ភដល់កូនរបស់ពួកគេ។

ទោះជាយ៉ាងណាក្តី ដំណើររបស់យើងនៅក្នុងស្រុកគូលែនក៏បានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងនៃភាពក្រីក្រ និងភាពខ្វះខាតផងដែរ។ ចាប់តាំងពីការរស់នៅដ៏តូចចង្អៀតរបស់ជីដូនដែលត្រូវមើលថែចៅៗជាច្រើននាក់ ទៅការមើលឃើញពីកុមារដែលភាពស្រងូតស្រងាត់ ទម្ងន់មិនគ្រប់ គឺសុទ្ធតែបានបង្ហាញពីតម្រូវការសកម្មភាពយ៉ាងចាំបាច់ និងជាបន្ទាន់ដោយមិនអាចប្រកែកបាន។ ក្នុងពេលដែលយើងកំពុងឆ្ពោះទៅដំណាក់កាលនៃការបង្កើតកម្មវិធីក្នុងតំបន់ថ្មីនៅគូលែន២ យើងក៏បានដឹងច្បាស់ពីកង្វះខាតជាច្រើនដែលយើងកំពុងជួបប្រទះ។ ទឹកស្អាត អាហារូបត្ថម្ភគ្រប់គ្រាន់ និងអនាម័យជាមូលដ្ឋានមិនមែនជារបស់ប្រណិតនោះទេ ប៉ុន្តែវាជាសិទ្ធិដ៏ចាំបាច់ដែលសហគមន៍ទាំងនេះមិនទទួលបាន។

ទោះបីជាទំហំនៃកិច្ចការបន្តទៅមុខមានភាពធំសម្បើមយ៉ាងណាក្តីក៏ខ្ញុំនៅតែមានក្តីសង្ឃឹម និងការតាំងចិត្តដ៏មុតមាំ។ ការណ៍ដែលយើងដឹងថាកិច្ចអន្តរាគមន៍របស់យើងមានឥទ្ធិពលក្នុងការផ្លាស់ប្តូរជីវិត នឹងជំរុញការប្តេជ្ញាចិត្តរបស់យើងឱ្យឈានបន្តទៅមុខទៀត។ ក្នុងពេលដែលយើងកំពុងកសាងមូលដ្ឋានគ្រឹះសម្រាប់កម្មវិធីថ្មីរបស់យើង យើងនឹងធ្វើដូច្នេះដោយភ្ជាប់ជាមួយនឹងគោលបំណង និងភាពបន្ទាន់។ កុមារគ្រប់រូបសមនឹងទទួលបានជីវិតមួយពេញដោយបរិបូណ៌ ហើយនេះជាទំនួលខុសត្រូវរួមរបស់យើងដើម្បីធានាថាចក្ខុវិស័យនេះនឹងក្លាយជាការពិត។



**អេនឌ្រូ ម៉ូលី**

ប្រធាន និងនាយកប្រតិបត្តិអង្គការទស្សនៈពិភពលោកអន្តរជាតិ

# តំបន់គោលដៅរបស់យើង




**៣៩**
តំបន់កម្មវិធី

**៤៧០**
ឃុំ

**៥៥**
ស្រុក

**២០**
ខេត្ត និងរាជធានីភ្នំពេញ

**២៧ ១៣៣ ៦១២ដុល្លារអាមេរិក**
ទឹកប្រាក់សរុបក្នុងឆ្នាំ២០២៣

**៥១៤នាក់**
បុគ្គលិក

# សមិទ្ធផលរបស់យើង

ផ្ដល់ផលដល់ប្រជាជនសរុបចំនួន

**៣ ២៧៣ ៩៧២ នាក់**

**៧៥២ ២៩៦**
ជាកុមារី

**៧៦៦ ៨១៣**
ជាកុមារា

**១ ៥១៩ ១០៩**
ចំនួនសរុបនៃកុមារ

**៩១៨ ២៥៥**
ជាស្ត្រី

**៨៣៦ ៦០៨**
ជាបុរស

**១ ៧៥៤ ៨៦៣**
ជាមនុស្សពេញវ័យ

# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

## ការរួមចំណែករបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា ដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

**1 គ្មានភាពក្រីក្រ**

ជារៀងរាល់ថ្ងៃ មានប្រជាជនចំនួន ៧គ្រួសារបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មឆ្លាតវៃខាងអាកាសធាតុប្រកបដោយភាពប្រសើរឡើង និងនិរន្តរភាពដើម្បីបង្កើននូវប្រាក់ចំណូល និងធានាបាននូវសន្តិសុខស្បៀងអាហារឱ្យកាន់តែប្រសើរឡើងសម្រាប់គ្រួសាររបស់ពួកគេ។

**4 ការអប់រំមានគុណភាព**

ជារៀងរាល់ម៉ោង មានកុមារចំនួន ៣នាក់ទទួលបានការគាំទ្រដើម្បីពង្រឹងនូវជំនាញអក្ខរកម្ម

**5 សមភាពយេនឌ័រ**

ស្រ្តីបានចូលរួមយ៉ាងសកម្មនៅក្នុងការសម្រេចចិត្តក្នុង ៨២% នៃគ្រួសារនៅតំបន់អនុវត្តកម្មវិធីរបស់អង្គការទស្សនៈពិភពលោក

**2 គ្មានភាពអត់ឃ្លាន**

ជារៀងរាល់ម៉ោង មានកុមារចំនួន ១០នាក់បានទទួលអាហារបំប៉ននៅតាមសាលារៀន

**6 ទឹកស្អាត និងអនាម័យ**

ជារៀងរាល់ថ្ងៃមានមនុស្សចំនួន ៥៧នាក់មានលទ្ធភាពទទួលបានទឹកស្អាត និងមនុស្សចំនួន ៦១នាក់ ទទួលបានសេវាកម្មអនាម័យមូលដ្ឋាន

**3 សុខភាពល្អ និងសុខុមាលភាព**

ក្នុងមួយថ្ងៃ មានកុមារចំនួន៣៤នាក់ (អាយុពី០-២៣ខែ) ត្រូវបានត្រួតពិនិត្យ និងគាំទ្រដោយបុគ្គលិកថែទាំសុខភាពតាមសហគមន៍

**16 សន្តិភាព និងយុត្តិធម៌**

៨៤% នៃអ្នកផ្តល់សេវាគ្រប់ដណ្តប់ដោយគម្រោងគណនេយ្យសង្គមរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា កំពុងដើរស្របទៅតាមលក្ខខណ្ឌស្តង់ដារថ្នាក់ជាតិ



# កម្មវិធីសុខភាព និងអាហារូបត្ថម្ភ

បង្កើននូវលទ្ធភាពទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភ និងលើកកម្ពស់ឥរិយាបថប្រកបដោយសុវត្ថិភាពក្នុងចំណោមស្រ្តីមានផ្ទៃពោះ និងកុមារអាយុក្រោមប្រាំឆ្នាំ។

- ការគាំពារ និងអភិវឌ្ឍន៍កុមារតូច (ECCD)៖ ការផ្លាស់ប្តូរឥរិយាបថជាមួយនឹង មាតា និងជីដូន
- ការសហការលើគម្រោងផ្តល់អាហារតាមសាលារៀនជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីស្បៀងអាហារពិភពលោក
- ការកែលម្អលើការកំណត់នូវអត្តសញ្ញាណ និងការបញ្ជូនកុមារដែលខ្វះអាហារូបត្ថម្ភ
- ការព្យាបាលបែបវេជ្ជសាស្រ្តដោយផ្ទាល់សម្រាប់កុមារ

# សមិទ្ធផលសំខាន់ៗ

អ្នកត្រួតពិនិត្យក្រុមមាតា(ECCD)ចំនួន **១៥៤នាក់** និងអ្នកសម្របសម្រួលក្រុមជីដូន(GMIA) ចំនួន ៧៣នាក់ត្រូវបានជ្រើសរើសពីក្រុមអ្នកគាំទ្រសុខភាពតាមភូមិ (VHSGs) ហើយត្រូវបានបណ្តុះបណ្តាល និងចូលរួមក្នុងការសម្របសម្រួលវគ្គប្រចាំខែ។

កុមារអាយុក្រោម៥ឆ្នាំចំនួន **២៨ ៥៨០នាក់**ត្រូវបានត្រួតពិនិត្យសម្រាប់បញ្ហាកង្វះអាហារូបត្ថម្ភ។

ជម្រកអាហារចំនួន **៤៣កន្លែង** អណ្ដូងស្នប់ចំនួន ៣០អណ្ដូង កន្លែងលាងដៃចំនួន ៥៧កន្លែង និងចង្ក្រានចំនួន ១៧ ត្រូវបាន សាងសង់ និងផ្ដល់ទៅ សាលា តាមរយៈកម្មវិធីផ្ដល់អាហារតាមសាលារៀន។

**ស្ត្រីចំនួន ១៥ ៥៥៥នាក់** និង ជីដូនចំនួន ១០ ២០៦នាក់ បានចូលរួមវគ្គផ្លាស់ប្តូរឥរិយាបថក្នុងសហគមន៍ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ECCD។

កុមារចំនួន **១ ២៦៣នាក់** ត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាកំពុងមានបញ្ហាកង្វះអាហារូបត្ថម្ភ និងទទួលបានការគាំទ្រនៅផ្ទះ ឬបញ្ជូនទៅមណ្ឌលសុខភាពក្បែរខ្លួនអាស្រ័យលើស្ថានភាពជាក់ស្តែង។



## លទ្ធផល

កុមារចំនួន **៧៩ ៤៦៦នាក់** ទទួលបានអាហារពេលព្រឹកប្រកបដោយភាពស្មើគ្នា កែលម្អអាហារូបត្ថម្ភ បង្កើននូវការចូលរៀន បង្កើនការយកចិត្តទុកដាក់ កាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។

ប្រាក់លើកទឹកចិត្តប្រចាំខែរបស់មេចុងភៅតាមសាលារៀន ចំនួន **៤១៥នាក់** (ស្ត្រីចំនួន ៣៣២ នាក់) ត្រូវបានរួមបញ្ចូលទៅក្នុងផែនការវិនិយោគឃុំ (ការចំណាយត្រូវបានចាត់ចែងដោយរាជរដ្ឋាភិបាល)។



ស្ត្រីចំនួន **៧ ១៦០នាក់** ដែលស្ថិតក្នុងវ័យបន្តពូជ (អាយុពី ១៥-៤៩ឆ្នាំ) និង កុមារចំនួន១០ ៦០៩នាក់ (អាយុពី០-៥៩ ខែ)ត្រូវបានគ្របដណ្តប់ តាមរយៈបុគ្គលិកសុខាភិបាលតាមសហគមន៍។




LEECO



# កម្មវិធីទឹកស្អាត និងអនាម័យ (WASH)

**កែលម្អនូវឥរិយាបថទាក់ទងនឹងទឹកស្អាត និងអនាម័យតាមរយៈកម្មវិធីផ្លាស់ប្តូរ ឥរិយាបថ និងហេដ្ឋារចនាសម្ព័ន្ធ សមស្រប។**

- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាត និងអនាម័យ
- ការផ្សព្វផ្សាយពីការបន្ទោបង់តាមបង្គន់អនាម័យ
- ការផ្សព្វផ្សាយពីកម្មវិធីទឹកស្អាត និងអនាម័យ តាមសាលាបឋមសិក្សា និងមណ្ឌលសុខភាព

## សមិទ្ធផលសំខាន់ៗ

ប្រជាជនចំនួន **៩ ៨៤៦គ្រួសារ** បានសាងសង់បរិក្ខារអនាម័យ។

ប្រជាជនចំនួន **១៧ ៧៨២គ្រួសារ** បានសាងសង់កន្លែងលាងដៃ។

ប្រជាជនចំនួន **១៥ ៦៧៩គ្រួសារ** ប្រើប្រាស់បច្ចេកវិទ្យាប្រព្រឹត្តកម្មទឹកស្អាត។

បណ្តុំប្រមូលទឹកថ្មីចំនួន **៤៣កន្លែង** ត្រូវបានតម្លើងនៅក្នុងគ្រឹះស្ថានសុខាភិបាល។

បរិក្ខារអនាម័យដែលបែងចែកតាមភេទ ចំនួន **២១កន្លែង** ត្រូវបានសាងសង់ក្នុងគ្រឹះស្ថានសុខាភិបាល។



## លទ្ធផល

ប្រជាជនចំនួន **៤៧ ៧៦២នាក់** ទទួលបានបរិក្ខារអនាម័យជាមូលដ្ឋានសម្រាប់ប្រើប្រាស់។

ឃុំចំនួន **៤៧ឃុំ**បានប្រកាសថាបានបញ្ឈប់ទាំងស្រុង នូវការបន្ទោបង់ពាសវាលពាសកាល។



ប្រជាជនចំនួន **៨៧ ៧០២នាក់** ទទួលបានកន្លែងលាងដៃភ្ជាប់ជាមួយនឹងសាប៊ូ និងទឹកសម្រាប់ប្រើប្រាស់។



ប្រជាជនចំនួន **៧៨ ៣៩៥នាក់** ទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់។





# ការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តភាព និងការអភិវឌ្ឍសហគ្រាស

កែលម្អប្រាក់ចំណូលគ្រួសារឱ្យមានភាពប្រសើរឡើង សម្រាប់គ្រួសារដែលងាយរងគ្រោះបំផុត ( សំដៅលើស្ត្រី ជនដែលមានពិការភាព និងយុវជន ) តាមរយៈសហគមន៍កសិកម្មក្នុងការសម្រេចបាននូវគោលដៅសុខុមាលភាពកុមារ។

## ▶ កសិកម្ម

ការផ្តល់នូវជំនួយសម្រួលជីវភាពដល់កសិករខ្នាតតូចលើធាតុចូលកសិកម្ម សម្ភារគ្រាប់ពូជ និងបច្ចេកទេសផ្សេងៗ។

ការពង្រឹងនូវសិទ្ធិអំណាចរបស់កសិករខ្នាតតូច ក្នុងអាជីវកម្មរួម ដោយភ្ជាប់ពួកគេជាមួយនឹងអ្នកផ្គត់ផ្គង់លើវិស័យកសិកម្ម និងភ្ជាប់ទំនាក់ទំនងការប្រមូលផ្តុំជាក្រុមទៅនឹងទីផ្សារទិន្នផល។

ការពង្រឹងនូវសមត្ថភាពកសិករខ្នាតតូចដើម្បីបង្កើនលទ្ធភាពទទួលបានអាហារ តម្លៃសមរម្យ និងភាពចម្រុះនៃអាហារ តាមរយៈកសិកម្មដែលផ្តោតលើអាហារូបត្ថម្ភ និងកសិកម្មឆ្លាតវៃខាងអាកាសធាតុ។

# គម្រោងអភិវឌ្ឍន៍វារីវប្បកម្មសម្រាប់និរន្តរភាពពាណិជ្ជកម្ម (ខាស់)

ការកែលម្អបច្ចេកទេសនិងសមត្ថភាព គ្រប់គ្រងរបស់អ្នកផលិតវារីវប្បកម្ម អ្នកផ្គត់ផ្គង់ និងអតិថិជនក៏ដូចជា ស្ថាប័នអប់រំដែលគាំទ្រលើឧស្សាហកម្ម វារីវប្បកម្ម។

ការពង្រឹងខ្សែសង្វាក់តម្លៃវារីវប្បកម្ម និង តួអង្គក្នុងទីផ្សារ។

កែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុ នៅ គ្រប់ដំណាក់កាលនៃខ្សែសង្វាក់តម្លៃ។

បង្កើននូវលទ្ធភាពទទួលបាន និង ទំនុកចិត្តលើត្រីដែលមានគុណភាពខ្ពស់ ដែលផលិត និងគ្រប់គ្រងតាមស្តង់ដារ អនាម័យត្រឹមត្រូវ។





# សមិទ្ធផលសំខាន់ៗ

ប្រជាជនចំនួន **៥៩៣គ្រួសារ**ទទួលបាននូវចំណេះដឹង និងជំនាញពាក់ព័ន្ធនឹងការអនុវត្តកសិកម្មផ្តោតលើអាហារូបត្ថម្ភ និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

ប្រជាជនចំនួន **៤១០គ្រួសារ**ទទួលបានធាតុចូលកសិកម្មចំនួន ២៤ដែលក្នុងនោះរួមមាន គ្រាប់ពូជបន្លែចំនួន៨ ប្រភេទ និង សម្ភារកសិកម្មចំនួន ១៦( ដូចជា ធុងស្តុកទឹក បំពង់ទឹក សំណាញ់ ) ដើម្បីផ្សព្វផ្សាយពីអាហារដែលមានអាហារូបត្ថម្ភ។

ប្រជាជនចំនួន **៨២គ្រួសារ**ទទួលបានដើមផ្លែផ្កា ដើម្បីលើកកម្ពស់ជីវភាព និងស្ថានភាពអាហារូបត្ថម្ភរបស់ពួកគេ។

**ផ្ទះកញ្ចក់ចំនួន ៧** កំពុងត្រូវបានដំឡើងដោយអ្នកសាងសង់សម្រាប់កសិករផ្ទើមចំនួន ៧រូប។

ប្រជាជនចំនួន **៤៨គ្រួសារ** បានទទួលកញ្ចប់ចិញ្ចឹមសត្វ។

ផែនទីហានិភ័យចំនួន **៦** និងកម្មវិធីស្តីពីការយល់ដឹងលើការត្រៀមខ្លួនទៅនឹងគ្រោះមហន្តរាយចំនួន ៦កម្មវិធីត្រូវបានធ្វើឡើងនៅ៦ឃុំ ក្នុង ៤ស្រុក។

អ្នកភូមិចំនួន **៦០០នាក់**បានចូលរួមក្នុងការបណ្តុះបណ្តាលការកសាងសមត្ថភាព (រួមមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ អក្ខរកម្មឌីជីថល សមភាពយេនឌ័រ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយ ) ។

អ្នកចូលរួមចំនួន **៣៧៦នាក់** ( ស្ត្រីចំនួន ៩១នាក់ ) បានចូលរួមក្នុងកិច្ចសន្ទនាអាជីវកម្មថ្នាក់ខេត្តចំនួន ៦កិច្ចសន្ទនា រួមបញ្ចូលទាំងតួអង្គក្រោយការប្រមូលផលចំនួន ១៣ រូបបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចសន្ទនាថ្នាក់ខេត្ត ហើយទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ក៏ត្រូវបានធ្វើឡើងដើម្បីផ្សារភ្ជាប់អ្នកទិញ និងអ្នកលក់។

សហគ្រាសធុនតូច និងមធ្យម(SMEs **ចំនួន ៧** បានទទួលការគាំទ្រលើម៉ាកយីហោ ផ្សព្វផ្សាយ និងទីផ្សារអនឡាញ ដើម្បីកែលម្អនូវសមត្ថភាព SMEs ដើម្បីចូលក្នុងទីផ្សារ និងបែងចែកផលិតផលចុងក្រោយ។

សហគ្រាសធុនតូច និងមធ្យមផ្នែកវារីវប្បកម្ម**ចំនួន ៤៣៣** ទទួលបានជំនួយបច្ចេកទេសលើទីផ្សារ រួមមានសហគ្រាសធុនតូច និងមធ្យមចំនួន ៩៣ ដែលបានទទួលជំនួយបច្ចេកទេសលើការរៀបចំផែនការអាជីវកម្មដើម្បីពង្រឹងទំនាក់ទំនងរវាងអ្នកទិញ និងអ្នកលក់។



## លទ្ធផល

សហគ្រាសធុនតូច និងមធ្យមចំនួន **៤០៧** បានទទួលជំនួយបច្ចេកទេសលើការទទួលបានសេវាហិរញ្ញវត្ថុ និងការប្រើប្រាស់ប្រាក់កម្ចីត្រឹមត្រូវរួមទាំងការចែករំលែកព័ត៌មានទីផ្សារ និងការសម្របសម្រួលផ្ទាល់មុខ។ ជាលទ្ធផល សហគ្រាសធុនតូច និងមធ្យមចំនួន ១៨៧ បានទទួលប្រាក់កម្ចីសរុបជាទឹកប្រាក់ចំនួន ៥ ២៥៨ ០៨៤ដុល្លារអាមេរិក។

សហគមន៍កសិកម្មចំនួន **២៨** ជាមួយនឹងសមាជិកចំនួន ៤ ០៤០នាក់ត្រូវបានពង្រឹងហើយឥឡូវនេះកំពុងគ្រប់គ្រងមូលធនសរុបជាទឹកប្រាក់ចំនួន ១ ២៧៤ ៣៧៧ដុល្លារអាមេរិក និងវិនិយោគ ៦ ៥០០ដុល្លារអាមេរិកចូលក្នុងសហគមន៍របស់ពួកគេវិញតាមរយៈមូលនិធិសង្គម។



# កម្មវិធីកិច្ចការពារ និងការចូលរួមរបស់កុមារ

## ធានាថាកុមារទទួលបានការការពារពីគ្រប់ទម្រង់នៃអំពើហិង្សា និងចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

ការបណ្តុះបណ្តាលជំនាញជីវិត គម្រោងដឹកនាំសហគមន៍ដោយយុវជន ការកសាងសមត្ថភាពរបស់ដៃគូក្នុងស្រុក និងមាតិកាដែលផ្តោតលើក្មេងវ័យជំទង់ត្រូវបានប្រើប្រាស់ដើម្បីបង្កើននូវជំនាញការពារ និងជាទុនអភិវឌ្ឍន៍សម្រាប់កុមារ និងក្មេងវ័យជំទង់និងទំនាក់ទំនងជាមួយមនុស្សពេញវ័យនិងមិត្តភក្តិរបស់គេ។

ការបណ្តុះបណ្តាលសម្រាប់ឪពុកម្តាយ អ្នកថែទាំ និងសហគមន៍ ដើម្បីជំរុញនូវទំនាក់ទំនងវិជ្ជមាន និងទប់ស្កាត់នូវទំនាក់ទំនងដែលអាចផ្តល់ផលគ្រោះថ្នាក់ដល់កុមារ និងក្មេងវ័យជំទង់។

ពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគីនិងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធដូចជារាជរដ្ឋាភិបាល ក្រុមជំនឿ និងក្រុមផ្សេងៗទៀតនៅក្នុងសហគមន៍ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃការរំលោភបំពាន។

ការចូលរួមជាមួយ និងការកសាងសមត្ថភាពភាគីពាក់ព័ន្ធក្នុងសហគមន៍ដើម្បីដោះស្រាយឬសគល់នៃអំពើហិង្សាលើកុមារ។

## សមិទ្ធផលសំខាន់ៗ

កុមារនិងក្មេងវ័យជំទង់ចំនួន **១៣ ១៧០នាក់** បានបញ្ចប់នូវការបណ្តុះបណ្តាលជំនាញជីវិត។

កុមារនិងក្មេងវ័យជំទង់ចំនួន **១៨ ៩៧៩នាក់** បានចូលរួមក្នុងក្លឹបយុវជន។

គម្រោងសិក្សាលើសេវាកម្មសហគមន៍ចំនួន **៣៦០** ត្រូវបានអនុវត្តន៍ដោយក្មេងវ័យជំទង់។

កុមារ និងយុវជនចំនួន **១៣៨នាក់** បានចូលរួមយ៉ាងសកម្មនៅក្នុងបណ្តាញថ្នាក់ជាតិ។

សមាជិកសហគមន៍ចំនួន **២៩ ៥០២នាក់**បានចូលរួមនៅក្នុងវគ្គសិក្សាលើការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថទាក់ទងនឹងបញ្ហាកិច្ចការពារកុមារ។

## លទ្ធផល

ឪពុកម្ដាយចំនួន **៩ ១៨០នាក់**បង្ហាញនូវការកើនឡើងផ្នែកចំណេះដឹងក្នុងការចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជមាន និងបញ្ហាផ្សេងៗពាក់ព័ន្ធនឹងកិច្ចការពារកុមារ។

**៩៨%** នៃសមាជិកសហគមន៍ដែលទទួលបានការបណ្ដុះបណ្ដាល ដឹងពីរបៀបឆ្លើយតបក្នុងករណីជួបប្រទះនឹងបញ្ហាទាក់ទងនឹងកិច្ចការពារកុមារ។

កុមារនិងយុវជនចំនួន **៣ ១៣៥នាក់** បានចូលរួមក្នុងយន្តការគណនេយ្យភាពសង្គមនៅលើបញ្ហាកិច្ចការពារកុមារ។

នៅចុងឆ្នាំ២០២៣ ប្រហែលជា **៩៩%** នៃសង្កាត់/ឃុំត្រូវបានរួមបញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ និង ៨៧% នៃសង្កាត់/ឃុំ ទាំងនោះបានបែងចែកថវិកាសេវាសង្គមរបស់ខ្លួនដើម្បីគាំទ្រដល់ការកែលម្អលើសមត្ថភាពប្រព័ន្ធការពារកុមារក្នុងស្រុក និងផ្តល់ផលជាវិជ្ជមានដល់កុមារជាង ៣៤០ ០០០នាក់ ក្នុងនោះមាន ១៧០ ០០០នាក់ជាកុមារី ៣ ៤០២នាក់ជាកុមារដែលមានពិការភាព និងក្នុងចំណោមពួកគេទាំងអស់មានកុមារងាយរងគ្រោះបំផុតចំនួន ២៣០ ០០០នាក់។

កុមារ និងយុវជនក្នុង **១០៦ឃុំ** បានចូលរួមជាមួយអាជ្ញាធរមូលដ្ឋានដើម្បីជំរុញឱ្យមានកែលម្អលើការអនុវត្តប្រព័ន្ធការពារកុមារក្នុងស្រុក។




ទម្រង់នៃអំពើហិង្សា
លើកុមារ
អំពើហិង្សាផ្លូវកាយ
អំពើហិង្សាផ្លូវចិត្ត
អំពើហិង្សាផ្លូវភេទ
SONY



# ការអប់រំបរិយាបន្ន

## បង្កើននូវចំនួនកុមារដែលទទួលបាននូវជំនាញអក្ខរកម្មសម្រាប់ជីវិត

ពង្រឹងសមត្ថភាពគ្រូបង្រៀនដើម្បីបញ្ចូលជំនាញអានជាស្ទួលទាំងប្រាំទៅក្នុងកម្មវិធីសិក្សារបស់ពួកគេ។

ការសហការលើគម្រោងផ្តល់អាហារតាមសាលារៀនជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធីស្បៀងអាហារពិភពលោក។

ផ្តល់ការបណ្តុះបណ្តាលដល់បណ្ណារក្ស នាយកសាលា និងលោកគ្រូ អ្នកគ្រូ និងចែកចាយសៀវភៅ និងសម្ភារសិក្សា ដើម្បីបំពេញតាមស្តង់ដារអប្បបរមាដែលបង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។

ការផ្ដល់សម្ភារអំណានកុមារមេត្រី និង លើកទឹកចិត្តឪពុកម្ដាយ អ្នកថែទាំដើម្បី រៀបចំទីតាំងសម្រាប់អាននៅផ្ទះ និង សកម្មភាពគាំទ្រអក្ខរកម្មដើម្បីជួយសម្រួល ដល់ការសិក្សាកូនៗរបស់ពួកគេ។

ការបង្កើតនូវជំរំអំណានដឹកនាំដោយ អ្នកសម្របសម្រួលការអានតាមសហគមន៍ ដែលទទួលបានការបណ្ដុះបណ្ដាលដោយ អង្គការទស្សនៈពិភពលោកដើម្បីជួយកុមារ ក្នុងការបង្កើនសមត្ថភាពនៃការអានរបស់ ពួកគេតាមរយៈវគ្គអក្ខរកម្មប្រចាំសប្ដាហ៍។

ជំរុញទំនាក់ទំនងរវាងវិស័យផ្លូវការ និងសហគមន៍ ដើម្បីសម្រេចបាននូវ គោលនយោបាយជាតិស្ដីពីការអប់រំនៅ បឋមសិក្សាប្រកបដោយគុណភាព។

ការចូលរួមជាដៃគូរួមគ្នាផ្ដល់ឱកាសអប់រំដល់ កុមារបាត់បង់ឱកាសនៅកម្ពុជា ដំណាក់កាល ទី ២ ការផ្សព្វផ្សាយលើ(១) លទ្ធភាពទទួល បានប្រកបដោយសមធម៌ (២) គុណភាព និង សារៈសំខាន់ និង (៣) ភាពជាម្ចាស់ការ និង គណនេយ្យភាពសម្រាប់កុមារក្រៅសាលា និង កុមារដែលងាយរងគ្រោះបំផុត។

## សមិទ្ធផលសំខាន់ៗ

អគារបណ្ណាល័យថ្មី ចំនួន **១៩ខ្នង**ត្រូវបានសាងសង់ និង បំពាក់ដោយសម្ភារអំណានតាមរយៈការប្រមូលនូវធនធាន សហគមន៍ដើម្បីគាំទ្រដល់ការសិក្សា និងទម្លាប់អានរបស់ សិស្សានុសិស្ស។

អគារបណ្ណាល័យចំនួន **៣០ខ្នង** ត្រូវបានជួសជុល ឡើងវិញ និងបំពាក់ដោយសម្ភារអំណានតាមរយៈការ ប្រមូលនូវធនធានសហគមន៍ ដោយមានការគាំទ្រពី អង្គការទស្សនៈពិភពលោក។

# សមិទ្ធផលសំខាន់។

សៀវភៅចំនួន **៩៩ ៦១៦ក្បាល** (២,៨៥៣ ចំណងជើង) ត្រូវបានចែកជូនតាមសាលារៀនចំនួន ៥៩០ ដើម្បីធានាឱ្យមាននូវធនធានអំណានដែលគាំទ្រដល់ការបង្រៀន និងការសិក្សា។

ទីតាំងសម្រាប់អាន(នៅផ្ទះ)ចំនួន **៧ ៤៤៤ទីតាំង** ត្រូវបានរៀបចំដោយឪពុកម្តាយ ឬអ្នកថែទាំដែលបានផ្តល់ជាផលប្រយោជន៍ដល់កុមារចំនួន ១១,៧២០នាក់។

ជំរំអំណានចំនួន **៩៧០កន្លែង** ត្រូវបានបង្កើតឡើងដោយផ្តល់នូវឱកាសសម្រាប់កុមារឱ្យមានពេលវេលារីករាយជាមួយនឹងការសិក្សាអក្ខរកម្មនៅក្នុងភូមិរបស់ពួកគេរៀងរាល់ចុងសប្តាហ៍។

អ្នកសម្របសម្រួលអំណានតាមសហគមន៍(CRF) ចំនួន **១ ៦៥២នាក់** (ស្ត្រីចំនួន ១ ៤៦៦នាក់)ត្រូវបានបណ្តុះបណ្តាលដើម្បីដឹកនាំវគ្គជំរំអំណាន និងសិក្ខាសាលាលើកកម្ពស់ការអានជាមួយឪពុកម្តាយ។

គ្រូបង្រៀនចំនួន **២ ៤៧៤នាក់** (ស្ត្រីចំនួន ១ ៣៩២នាក់) បានចូលរួមការបណ្តុះបណ្តាលយ៉ាងពេញលេញលើវិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។

សមាជិកគណៈកម្មការសាលា និងអាជ្ញាធរមូលដ្ឋានចំនួន **៧៤០នាក់** (មានស្ត្រីចំនួន ២៤៤នាក់)ត្រូវបានបណ្តុះបណ្តាលដើម្បីគាំទ្រដោយផ្ទាល់ដល់ការអនុវត្តកម្មវិធីអប់រំនៅក្នុងសាលារៀនរបស់ពួកគេ។

គ្រូបង្រៀនថ្នាក់ទី ១-៣ ចំនួន **២ ៤៨៥នាក់** (ស្ត្រីចំនួន ១ ៥១២នាក់)ត្រូវបានបណ្តុះបណ្តាលដោយជោគជ័យក្នុងវគ្គបណ្តុះបណ្តាលគ្រូពីវិធីសាស្ត្រកុមាររៀន កុមារចេះ។

កុមារចំនួន **១១ ៣៩៩នាក់** បានទទួលជំនួយជាសម្ភារ (កង់ កាបូបស្ពាយ សម្ភារសិក្សា សៀវភៅជំនួយបន្ថែម)ដើម្បីចូលរៀន។

# លទ្ធផល

សាលារៀនចំនួន **៧៨សាលា** បានប្រជុំប្រចាំត្រីមាសជាមួយឪពុកម្ដាយ អ្នកថែទាំរបស់កុមារដែលរៀនយឺត ដើម្បីស្វែងរកវិធីគាំទ្រពួកគេទាំងនៅសាលារៀន និងនៅផ្ទះ។

កុមារចំនួន **២១ ៩២០នាក់** បានចូលរៀនថ្នាក់បំប៉ន។







# គណនេយ្យភាពសង្គម

## ការអនុវត្តកម្មវិធីក្របខណ្ឌគណនេយ្យភាពសង្គម (ISAF)

ប្រជាពលរដ្ឋត្រូវបានជូនដំណឹងអំពីសេវាកម្មដែលពួកគេមានសិទ្ធិទទួលបាន។ កិច្ចសន្ទនាជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបានជំរុញ ហើយសកម្មភាពរួមគ្នាដើម្បីដោះស្រាយបញ្ហាត្រូវបានកំណត់ និងអនុវត្តន៍។

**ប្រជាជនដែលគ្របដណ្តប់ដោយកម្មវិធី៖** ៣ ៧៤៦ ៨៤៥ នាក់ (ស្រ្តីចំនួន ១ ៦៧៤ ៤៣៧ នាក់) កុមារចំនួន ១ ៣៧៨ ៨៣៩នាក់(កុមារីចំនួន ៦៦៩ ០៥៩នាក់) និង កុមារដែលងាយរងគ្រោះបំផុត ចំនួន ៩២៥ ៤៧៥នាក់ (កុមារីចំនួន ៤៤៤ ៨០៣នាក់)

# ▶ វដ្តប្រចាំឆ្នាំនៃគម្រោងក្របខណ្ឌគណនេយ្យភាពសង្គម ដំណាក់កាលទី ២



## ▶ សមិទ្ធផលសំខាន់ៗ

ប្រជាពលរដ្ឋជាង **១ លាននាក់** (ស្ត្រី ៧០%) និងមន្ត្រីបានចូលរួមក្នុងសិក្ខាសាលាដើម្បីកំណត់នូវបញ្ហាដែលប៉ះពាល់ដល់គុណភាពនៃសេវាកម្មនៅក្នុងសហគមន៍របស់ពួកគេ និងអភិវឌ្ឍន៍ផែនការសកម្មភាពដើម្បីដោះស្រាយបញ្ហាដែលមាន។
ក្នុងនោះរួមមាន៖

- **៤៨%**ជាគ្រួសារក្រីក្រ
- **៥ ៣៩៩នាក់**ជាជនដែលមានពិការភាព (ស្ត្រីចំនួន ២ ៨១៩នាក់)
- **៨ ៤៨៩នាក់** ជាជនជាតិភាគតិច (ស្ត្រីចំនួន ៦ ៦០៧នាក់)

អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍(CAFs) ចំនួន **១ ៩៦៤នាក់** (ស្ត្រី ៦៩%) រួមទាំងជនបាត់បង់ឱកាស ត្រូវបានបណ្តុះបណ្តាលនិងកំពុងបំពេញភារកិច្ចយ៉ាងសកម្ម។

**៦០%** នៃ៤០០ឃុំ/សង្កាត់ដែលបានបង្កើតផែនការសកម្មភាពរួមគណនេយ្យភាព (JAAP) បានធ្វើការប្រជុំលើការត្រួតពិនិត្យយ៉ាងហោចណាស់បានមួយដង។



# លទ្ធផល

ការអនុវត្តផែនការសកម្មភាពរួម គណនេយ្យភាពបាននាំមកនូវការកែលម្អសេវាកម្មដែលផ្តល់ដោយរដ្ឋបាលឃុំ ចំនួន **៤៧០** ហើយមណ្ឌលសុខភាព ចំនួន **៣៧៩មណ្ឌល** និង សាលាបឋមសិក្សាចំនួន **២ ០៨៨** ត្រូវបានប្រើប្រាស់ដោយប្រជាពលរដ្ឋជាង ៣ ៧ លាននាក់(ស្ត្រីចំនួន ១ ៦៧ លាន នាក់) រួមទាំង ១ ៣លាននាក់ជាកុមារ។

ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទង នឹងសិទ្ធិ និងស្តង់ដារសេវាសាធារណៈ បានកើនឡើងពី**៦៩%** ក្នុងឆ្នាំ ២០២០ ទៅដល់ **៧៥%** ក្នុងឆ្នាំ ២០២៣។

នៅឆ្នាំ ២០២២ ប្រជាពលរដ្ឋ **៧៥%** ដែលបានចូលរួមក្នុងដំណើរការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ បានរាយការណ៍ពីការកើនឡើងនូវទំនុកចិត្តនៃសំឡេងនិងសកម្មភាពរបស់ប្រជាពលរដ្ឋថាអាចផ្តល់ផលជាវិជ្ជមានលើគុណភាពសេវាសាធារណៈ។








# ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះមហន្តរាយ

ការគ្រប់គ្រងគ្រោះមហន្តរាយ ធានាថាបុគ្គល ក្រុមគ្រួសារ និងសហគមន៍ជាពិសេសកុមារដែលងាយរងគ្រោះបំផុត កាន់តែមានភាពធន់ទៅនឹងផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដើម្បីទ្រទ្រង់សុខុមាលភាពរបស់កុមារ។

# សមិទ្ធផលសំខាន់។

សមាជិកចំនួន **២៣៦នាក់** (ស្ត្រីចំនួន ៦១នាក់)នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ(DMC) និងសមាជិកសហគមន៍ចំនួន ២ ៧២០នាក់ (ស្ត្រីចំនួន ៩០៧នាក់) បានទទួលការបណ្តុះបណ្តាលលើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

សិស្សចំនួន **៦,៧១៣នាក់** (សិស្សស្រីចំនួន ៣ ១២៦នាក់) ត្រូវបានបណ្តុះបណ្តាលអំពីការត្រៀមខ្លួន និងរបៀបការពារខ្លួនពីគ្រោះមហន្តរាយ។

សមាជិកសហគមន៍ចំនួន **៤៨ ២០៥នាក់** (ស្ត្រីចំនួន ២ ៧៤៣នាក់)បានអភិវឌ្ឍន៍ផែនការក្នុងការអនុវត្តសកម្មភាព ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ(DRR/CC) ។

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតាមសាលារៀន (SDMC) ចំនួន **១៨៩** ក្នុងនោះមានសមាជិកជាស្ត្រីចំនួន ៧៥នាក់ ទទួលបានការកសាងសមត្ថភាព លើការគ្រប់គ្រងគ្រោះមហន្តរាយ DM ក្របខណ្ឌសាលារៀនមានសុវត្ថិភាព SSF និងរបៀបអភិវឌ្ឍផែនការដើម្បីត្រៀមខ្លួននឹងគ្រោះមហន្តរាយ។



# លទ្ធផល

ឃុំចំនួន **៣១ឃុំ** បានរួមបញ្ចូលនូវសកម្មភាពការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំ។

សមាជិកចំនួន **១ ៥៧៩នាក់** (ស្ត្រីចំនួន ៩៧០នាក់) នៃក្រុមសហគមន៍ចំនួន ៥២ក្រុម ក្នុង៣២ភូមិ ២៣ឃុំ និង ៧ ស្រុកបានអភិវឌ្ឍន៍ផែនការគ្រប់គ្រងហានិភ័យ និងផែនការត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយដែលអាចកើតមាននាពេលអនាគត។

ប្រជាជនចំនួន **២ ១៥០គ្រួសារ** ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ ដោយរួមមានកុមារចំនួន ៤ ៣៤៥ នាក់ (កុមារីចំនួន ២ ៤០៦ នាក់) ដែលទទួលបានផលជាវិជ្ជមានតាមរយៈការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា។



តម្រូវការជាមូលដ្ឋាន ការគាំទ្រផ្នែកអាហារ និងសម្ភារសម្រាប់សាងសង់ជម្រកនិងដំបូលឡើងវិញត្រូវបានផ្តល់ជូនដល់ **៤០៥គ្រួសារ** និងសាលាបឋមសិក្សាចំនួន ២ ស្ថិតក្នុងឃុំចំនួន ៦ឃុំ កំឡុងពេលឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ដែលបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនចំនួន ២ ៣៤៥នាក់ រួមមានស្ត្រីចំនួន ១ ២៦៤ នាក់ កុមារចំនួន ៧៩៨ នាក់(កុមារីចំនួន ៤៩៨ នាក់) និងជនដែលមានពិការភាពចំនួន ៣នាក់(ស្ត្រីចំនួន១ នាក់)។


ក្រុមសង្គ្រោះបឋម
ក្រុមសង្គ្រោះបឋម



# សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)

សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) គឺជាកត្តាសំខាន់ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលបំពេញនូវយុទ្ធសាស្ត្រ "ការសន្យារបស់យើង" របស់អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា និងការសម្រេចបាននូវគោលដៅសុខុមាលភាពកុមារ។

នៅឆ្នាំ២០២៣ អង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា បានធ្វើការវិភាគពេញលេញលើស្ថាប័ន និងកម្មវិធី GEDSI។ លទ្ធផលដែលទទួលបាននឹងត្រូវដាក់បញ្ចូល និងបញ្ជាក់បន្ថែមនៅឆ្នាំ២០២៤។ សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ ២០២៣ រួមមាន៖

**៤៨%** នៃកុមារចំនួន១ ៥១៩ ១០៩នាក់ ដែលត្រូវបានគ្របដណ្តប់ដោយកម្មវិធីជាកុមារី។

**៦៤%** នៃស្ត្រីនិងក្មេងប្រុសវ័យជំទង់បានរាយការណ៍ថាបានកែលម្អប្រសិទ្ធភាពផ្ទាល់ខ្លួន។

ស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុង**៨២%** នៃគ្រួសារនៅតំបន់គោលដៅកម្មវិធីរបស់អង្គការទស្សនៈពិភពលោក។

ស្ត្រីចំនួន **៧៧៩នាក់**បានចូលរួមក្នុងសកម្មភាពបង្កើនប្រាក់ចំណូល។





# ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

អង្គការទស្សនៈពិភពលោកប្រចាំនៅកម្ពុជា បានអនុវត្តន៍វិធីសាស្ត្រកសិកម្មឆ្លាតវៃខាងអាកាសធាតុដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ទៅលើការផលិតអាហារ។ ការអនុវត្តនេះអាចឱ្យកសិករកាត់បន្ថយនូវផលប៉ះពាល់បរិស្ថាន ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ និងបង្កើនផលិតភាពតាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ដូចជាមន្ទីរកសិកម្មតាមខេត្ត អ្នកសម្របសម្រួលទីផ្សារក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ អ្នកចូលរួមកម្មវិធីត្រូវបានបណ្តុះបណ្តាលឱ្យយល់ដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការផលិតអាហារ និងធាតុផ្សំសំខាន់ៗក្នុងការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុ ដែលមានដូចជាផលិតកម្ម ការសម្របខ្លួន និងការកាត់បន្ថយ។ លើសពីនេះ កសិករក៏ត្រូវបានបណ្តុះបណ្តាលពីកិច្ចអន្តរាគមន៍ទាក់ទងនឹងកសិកម្មឆ្លាតវៃខាងអាកាសធាតុដូចជា ការធ្វើកម្មវិធីដាំដំណាំ រុក្ខាប្រមាញ់ កសិកម្មអភិរក្ស ការកែលម្អការគ្រប់គ្រងទឹក ការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នាការគ្រប់គ្រងការចិញ្ចឹមសត្វ ការជ្រើសរើសពូជដំណាំ ការបង្កើតប្រតិទិនដំណាំ និងការគ្រប់គ្រងដី។

គិតរហូតមកដល់ខែកញ្ញា ឆ្នាំ២០២៣ កសិករសរុបចំនួន ២ ៨៤៩នាក់ បានឆ្លងកាត់នូវការបណ្តុះបណ្តាល ដែលនេះជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការពង្រឹងនូវសិទ្ធិអំណាចក្នុងវិស័យកសិកម្ម និងការដាំដុះ។ ក្នុងនោះមានកសិករចំនួន ១ ៦១៤នាក់ ជាស្ត្រី និង ៨២នាក់ ជាកសិករដែលមានពិការភាព (ស្ត្រីចំនួន ៥នាក់) ដែលបានចូលរួម និងសម្តែងនូវការប្តេជ្ញាចិត្តក្នុងការជំរុញភាពងាយស្រួល និងភាពចម្រុះនៅក្នុងសហគមន៍កសិកម្ម។ នៅពេលបញ្ចប់នៃវគ្គបណ្តុះបណ្តាល សមាជិកទាំងនេះបានទទួលការគាំទ្រដូចជាធាតុផ្សំកសិកម្ម និងលទ្ធភាពទទួលបានឥណទាន និងប្រាក់កម្ចី។ កសិករមួយចំនួនក៏ត្រូវបានគាំទ្រតាមរយៈផ្ទះកញ្ចក់ ដែលនេះសង្កត់ធ្ងន់លើអភិក្រមនៃការចូលរួម ដែលកសិករបានរួមចំណែកក្នុងការផ្គត់ផ្គង់សម្ភារកសិកម្ម និងសម្ភារផ្សេងទៀតសម្រាប់ការធ្វើផ្ទះកញ្ចក់។ នេះមិនត្រឹមតែជំរុញឱ្យមានភាពជាម្ចាស់ និងការចូលរួមប៉ុណ្ណោះទេ ប៉ុន្តែក៏បានលើកទឹកចិត្តឱ្យមានការអនុវត្តប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍ផងដែរ។ នៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ អ្នកចូលរួមត្រូវបានតម្រូវឱ្យបង្កើតនូវផែនការសម្រាប់ការដាំដុះដំណាំ។ ការបន្តតាមដាន និងការបង្វឹកដែលផ្តល់ដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា អនុញ្ញាតឱ្យពួកគេប្រកាន់ខ្ជាប់នូវការអនុវត្តវិធីសាស្ត្រកសិកម្មឆ្លាតវៃខាងអាកាសធាតុ ដែលប្រកបដោយនិរន្តរភាព។





# ការតស៊ូមតិ និងយុទ្ធនាការ

- តាមរយៈយន្តការគណនេយ្យភាពសង្គម ទឹកប្រាក់សរុបចំនួន **១ ៦៣២ ២១៦ ដុល្លារអាមេរិក** ត្រូវបានបែងចែកដោយស្ថាប័នរាជរដ្ឋាភិបាលក្នុងស្រុក ដើម្បីលើកកម្ពស់គុណភាពនៃការសិក្សា នៅតាមសាលាបឋមសិក្សា
- អាជ្ញាធរមូលដ្ឋានក៏បានបែងចែកថវិកាបន្ថែមចំនួន **៣៨១ ៤៣០ ដុល្លារអាមេរិក** ដើម្បីកែលម្អនូវគុណភាពនៃការផ្តល់សេវាថែទាំសុខភាព
- ថវិកាជាង **២៤៨ 000 ដុល្លារអាមេរិក** ត្រូវបានបែងចែកពីថវិកាឃុំ សង្កាត់ដើម្បីពង្រឹងយន្តការកិច្ចការពារកុមារនៅថ្នាក់ឃុំដែលជាលទ្ធផលនៃការតស៊ូមតិដឹកនាំដោយប្រជាពលរដ្ឋផ្ទាល់
- ជាលទ្ធផលនៃកិច្ចសន្ទនា និងការតស៊ូមតិក្នុងទិវាជាតិអំណាន សាលារៀនបានពង្រឹងស្តង់ដារ និងសេវាកម្មបណ្ណាល័យរបស់ពួកគេ ដើម្បីបង្កើនលទ្ធភាពទទួលបានសម្ភារអំណានដែលមានគុណភាពសម្រាប់កុមារចំនួន **១៤ ៩៧២ នាក់។**

## អង្គការទស្សនៈពិភពលោកបានធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីរៀបចំបង្កើតនូវ៖

- **ប្រកាសលេខ ២១៤ ស្តីពីក្រមសីលធម៌ការងារសង្គមកិច្ចឆ្នាំ ២០២៣៖** ពង្រឹងនូវក្រមសីលធម៌ សេចក្តីថ្លៃថ្នូរ ប្រសិទ្ធភាព និងគុណភាពនៃការងារសង្គមកិច្ច និងអ្នកផ្តល់សេវាសង្គមផ្សេងៗនៅប្រទេសកម្ពុជា។
- **ប្រកាសលេខ ២៣៣ ស្តីពីក្រមសីលធម៌សម្រាប់កិច្ចការពារកុមារឆ្នាំ ២០២៣៖** បង្កើតនូវក្រមសីលធម៌ក្នុងការចាត់នូវវិធានការទប់ស្កាត់ លុបបំបាត់ និងឆ្លើយតបចំពោះរាល់ទម្រង់នៃការរំលោភបំពានលើកុមារ និងការពារសិទ្ធិ សុវត្ថិភាព សុខុមាលភាព និងសេចក្តីថ្លៃថ្នូររបស់កុមារគ្រប់រូប។



# ដៃគូរបស់យើង

យើងខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះដៃគូរបស់យើង សម្រាប់ការប្តេជ្ញាចិត្តជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់កុមារងាយរងគ្រោះបំផុតនៅកម្ពុជា។

## រាជរដ្ឋាភិបាលកម្ពុជា

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)
- រដ្ឋបាលថ្នាក់ក្រោមជាតិ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល កែប ក្រចេះ កំពង់ចាម ឧត្តរមានជ័យ ប៉ៃលិន ព្រះសីហនុ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ និងត្បូងឃ្មុំ ក៏ដូចជារាជធានីភ្នំពេញ។

## អង្គការសង្គមស៊ីវិល / ដៃគូអនុវត្តន៍ក្នុងស្រុក

- អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ (AFD)
- អង្គការ អេដ អេ អាកស្យុង (AeA)
- អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA)
- អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP)
- អង្គការស្អាតកម្ពុជា
- អង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS)
- អង្គការពន្លឺកុមារ
- អង្គការរីដា (READA)
- អង្គការសុវណ្ណភូមិ
- អង្គការស្តារកម្ពុជា
- អង្គការវឌ្ឍនភាព (WP)

## ដៃគូក្រុមហ៊ុន/ មូលនិធិ

- វិទ្យាស្ថាន Agro-Food New Marketing Institute (NEWMA)
- សមាគមសណ្ឋេកសៀងអាមេរិក
- សាលា CamEd Business School
- ក្រុមហ៊ុន Eco-Soap
- សភាយុវពាណិជ្ជករអន្តរជាតិកម្ពុជាសាខាចតុមុខ
- មូលនិធិ ម៉េងលី ជេ. គួច
- ក្រុមហ៊ុន Procter and Gamble (P&G)
- ក្រុមសកម្មភាពអនាម័យ (SAG)
- មូលនិធិ Trailblazer Foundation
- មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍មូលនិធិទឹក
- បណ្តាញគ្រឹះស្ថានអប់រំ វេសឡាញ អេឌ្យូខេសិន គ្រុប

# ដៃគូអភិវឌ្ឍន៍

Australian Government
Department of Foreign Affairs and Trade

Federal Ministry
for Economic Cooperation
and Development

MOFA
Japan

Aide et Action
becomes
ACTION EDUCATION

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

UNDP

USDA

WORLD BANK GROUP

WFP
World Food Programme

World Vision®

# របាយការណ៍ហិរញ្ញវត្ថុ

## ប្រភេទមូលនិធិ




- គម្រោងហិរញ្ញប្បទានឥតសំណង
- មូលនិធិឯកជន (ម្ចាស់ជំនួយធំៗ)
- មូលនិធិឯកជន (កម្មវិធីទំនុកបម្រុង)

## ថវិកា និងសូចនាករដោយការចំណាយតាមវិស័យ




- កិច្ចការពារកុមារ និងការវិនិយោគលើបំណិនជីវិតរបស់យុវជន
- ការចូលរួមរបស់សហគមន៍ដើម្បីពង្រឹងភាពជាម្ចាស់
- ការប្រកបរបរចិញ្ចឹមជីវិត និងភាពធន់ផ្នែកសេដ្ឋកិច្ច
- ការអប់រំ និងការអភិវឌ្ឍន៍បំណិនជីវិត
- សុខភាព និងអាហារូបត្ថម្ភ (រួមបញ្ចូលទាំងជំងឺឆ្លង )
- ទឹកស្អាត និងអនាម័យ (WASH)

# ឧបសម្ព័ន្ធ












# រឿងនៃការផ្លាស់ប្តូរ

## ដំណើររបស់ឆាត់ ឆ្ពោះទៅរកការបញ្ឈប់ទាំងស្រុងនូវការបន្ទោបង់ពាសវាលពាសកាល និងលើកកម្ពស់ការយល់ដឹងពីអនាម័យ

ពីក្មេងស្រីដែលមានអាយុ ១៤ ឆ្នាំហើយបានបាត់បង់នូវម្តាយពីក្មេងវ័យ ឆាត់បានចាប់យកឱកាសធ្វើជាអ្នកស្ម័គ្រចិត្តដើម្បីសុខុមាលភាពកុមារនៅពេលដែលអង្គការទស្សនៈពិភពលោក បានចាប់ផ្តើមប្រតិបត្តិការនៅក្នុងភូមិរបស់នាងក្នុងស្រុកសំរោង។ សព្វថ្ងៃនេះនៅអាយុ ២៨ឆ្នាំ ឆាត់បានវិវត្តខ្លួនទៅជាអ្នកតស៊ូមតិយ៉ាងសកម្មក្នុងសហគមន៍ ជាសមាជិកក្លឹបយុវជន ហើយក៏ជាដៃគូសហគមន៍តែម្នាក់គត់សម្រាប់កម្មវិធីទឹកស្អាត និងអនាម័យ ដោយចូលរួមក្នុងក្រុមដឹកនាំដោយសហគមន៍ក្នុងការបញ្ឈប់ទាំងស្រុងនូវការបន្ទោបង់ពាសវាលពាសកាល (CLTS) ជាមួយអង្គការទស្សនៈពិភពលោក។



បន្ទាប់ពីមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់រយៈពេល ១៤ឆ្នាំរបស់អាជ្ញាធរមូលដ្ឋាន ដៃគូ និងយុវតីរូបនេះផ្ទាល់ ភូមិសំរោងក៏ត្រូវបានប្រកាសថាបានបញ្ឈប់ទាំងស្រុងនូវការបន្ទោបង់ពាសវាលពាសកាល (ODF) ហើយក៏បានក្លាយជាភូមិដំបូងគេបង្អស់នៅក្នុងស្រុកសំរោងដែលទទួលបានការទទួលស្គាល់នេះក្នុងឆ្នាំ ២០១១។

ជាក្មេងស្រីម្នាក់ដែលមិនធ្លាប់ទទួលបានការណែនាំលើបញ្ហាអនាម័យត្រឹមត្រូវ នាងបានរំលឹកថា "វាពិតជាគ្រោះថ្នាក់ខ្លាំងណាស់សម្រាប់កុមារ ជាពិសេសកុមារីដែលត្រូវទៅបន្ទោបង់ម្នាក់ឯងនៅក្នុងព្រៃ ហើយក៏ជាការព្រួយបារម្ភចំពោះសុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេផងដែរ។ ខ្ញុំធ្លាប់បានឆ្លងកាត់បទពិសោធន៍នេះរួច ហើយក៏យល់ពីអារម្មណ៍អ្នកដែលស្ថិតក្នុងស្ថានភាពនេះដែរ"។

អ្នកស្រុកម្នាក់ឈ្មោះ ស៊ន ដែលមានអាយុ ៦៧ឆ្នាំ បានកែលម្អជីវភាពរស់នៅរបស់គ្រួសារគាត់ ដោយធ្វើការសាងសង់នូវបង្គន់អនាម័យក្នុងផ្ទះ ផ្តល់ឱ្យគ្រួសារគាត់មាននូវបរិក្ខារអនាម័យប្រកបដោយសុវត្ថិភាព និងភាពថ្លៃថ្នូរ។ស៊នបានលើកឡើងថា៖ “កាលពីឆ្នាំ២០១១ បន្ទាប់ពីក្រុមការងារគោលដៅបានចុះមកផ្សព្វផ្សាយចំណេះដឹងក្នុងភូមិខ្ញុំរួច ភ្លាមៗនោះខ្ញុំបានប្រមូលប្រាក់សន្សំ និងលក់មាន់របស់ខ្ញុំដើម្បីសាងសង់បង្គន់ផ្ទាល់ខ្លួន”។

លោក ឃិន ឃីម ជាមេភូមិ និងអ្នកដឹកនាំក្រុម CLTS នៅក្នុងភូមិតាំងពីឆ្នាំ ២០០៩ បានលើកឡើងថា៖ “ដរាបណាអ្នកភូមិនៅតែមានឆន្ទៈក្នុងការសាងសង់បង្គន់អនាម័យ យើងនឹងព្យាយាមជួយពួកគេអស់ពីលទ្ធភាពរបស់យើង។ ពេលខ្លះសមាជិករបស់យើង ថែមទាំងជួយសាងសង់បង្គន់ និងផ្តល់នូវសម្ភារទៅតាមលទ្ធភាពដែលយើងអាចធ្វើទៅបាន”។ គាត់បន្តថា៖ “ខ្ញុំចង់ឃើញអ្នកភូមិក្នុងសហគមន៍ខ្ញុំ បន្តអនុវត្តន៍វិធីសាស្រ្តអនាម័យបានល្អខ្ជាប់ខ្ជួន និងពាំនាំនូវការយល់ដឹងពីការសាងសង់បង្គន់អនាម័យនៅតាមផ្ទះរបស់ពួកគេ”។



## យ៉ារុ៖ ដំណើរឆ្ពោះទៅរកការផ្លាស់ប្តូរ ក្នុងនាមជាអ្នកដឹកនាំយុវជន និងអ្នកតស៊ូមតិដើម្បីបញ្ឈប់អំពើហិង្សាលើកុមារ

យុវតីយ៉ារុ អាយុ១៦ឆ្នាំ ជាយុវជនតស៊ូមតិ និងជាអ្នកដឹកនាំយុវជនក្នុងសហគមន៍បានលើកឡើងថា៖ "គ្រួសារមួយចំនួនក្នុងសហគមន៍របស់ខ្ញុំ ខ្វះនូវការយល់ដឹងអំពីការរំលោភបំពានលើកុមារ និងជឿថាការអប់រំកូនដោយប្រើអំពើហិង្សាគឺជារឿងធម្មតា ដែលនេះស្រដៀងនឹងអ្វីដែលសង្គមយើងគិតថាជារឿងធម្មតា ដែលការពិតទៅ មិនដូច្នោះនោះទេ ហើយជាទូទៅ ពួកគេ តែងមើលរំលងនូវបញ្ហាដ៏សំខាន់មួយនេះ។ ដូចនេះហើយទើបយុវជនដូចរូបខ្ញុំ ត្រូវតែបន្តតស៊ូមតិសម្រាប់កុមារដែលពុំមានសំឡេង និងមិនអាចចេញមុខការពារខ្លួនគេបាន"។

ការខិតខំប្រឹងប្រែងរបស់យ៉ារុ មិនមែនមានតែនៅក្នុងសហគមន៍របស់នាងឡើយ ដោយយុវតីរូបនេះ ត្រូវបានអញ្ជើញឱ្យឡើងចែករំលែកបទពិសោធន៍នៅ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅទីក្រុងញូវយ៉កក្នុងខែឧសភាឆ្នាំ ២០២៣ កន្លងទៅនេះ។ យ៉ារុមានភាពឧស្សាហ៍ព្យាយាមធ្វើការជាមួយអង្គការទស្សនៈពិភពលោកអន្តរជាតិ ប្រចាំនៅកម្ពុជា ហើយនាងក៏កំពុងបំពេញនូវតួនាទីជាអ្នកដឹកនាំក្លឹបយុវជន ដោយផ្តោតលើការលុបបំបាត់អំពើហិង្សាលើកុមារ និងធ្វើការដោយមិននឿយហត់ដើម្បីជំរុញ និងលើកទឹកចិត្តការចូលរួមរបស់យុវជននៅក្នុងសហគមន៍របស់នាងផងដែរ។



យ៉ារុបានបន្តថា៖ "ខ្ញុំតែងមានភាពអាត្មានិយមទាក់ទងនឹងចំណេះដឹងរបស់ខ្ញុំ ប៉ុន្តែចាប់តាំងពីបានចូលរួមការងារសហគមន៍រួចមក ខ្ញុំបានយល់ថាការចែករំលែកចំណេះដឹង និងការជួយមនុស្សគឺជាសកម្មភាពដ៏ល្អបំផុត ដែលនេះកាន់តែធ្វើឱ្យខ្ញុំសប្បាយចិត្តថែមទៀត"។

យ៉ារុ សហការជាមួយដៃគូសហគមន៍ និងអាជ្ញាធរដើម្បីលើកកម្ពស់ការចិញ្ចឹមបីបាច់កូនតាមបែបវិជ្ជមាន និងលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ពីឥទ្ធិពលនៃអំពើហិង្សាលើរាងកាយ និងសុខុមាលភាពផ្លូវចិត្តរបស់កុមារ។

នាងបានបញ្ជាក់ថា អំពើហិង្សាលើកុមារមិនត្រឹមតែជាបញ្ហាផ្ទាល់ខ្លួនដែលប៉ះពាល់ដល់សុខុមាលភាពកុមារនោះទេ ប៉ុន្តែក៏ជាបញ្ហាប្រឈមក្នុងសហគមន៍ និងសកលលោកដែលត្រូវតែដោះស្រាយ។ យ៉ារុបានបន្ថែម “បញ្ហាមួយទៀតដែលខ្ញុំឃើញក្នុងសហគមន៍របស់ខ្ញុំនោះ គឺទាក់ទងនឹងផលប៉ះពាល់នៃជំងឺកូវីត១៩។ យុវជននៅភូមិខ្ញុំត្រូវនៅផ្ទះកំឡុងពេលបិតខ្ទប់ ហើយបានយកទូរស័ព្ទរបស់ពួកគេជាមិត្ត ប៉ុន្តែពួកគេ នៅតែបន្តឥរិយាប័ទបែបនេះនៅពេលដែលយើងត្រឡប់ចូលសាលារៀនវិញ។ ចំពោះបញ្ហានេះ ខ្ញុំនឹងសហការជាមួយក្រុមរបស់ខ្ញុំដើម្បីធ្វើការសិក្សាលើប្រធានបទផ្តោតពីផលប៉ះពាល់នៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមច្រើនហួសកំណត់”។

មានសម្រង់ពាក្យមួយពោលថា៖ “កុំក្លាយជាមនុស្សដែលមិនដែលចាញ់ ត្រូវក្លាយជាមនុស្សដែលមិនចុះចាញ់”។ នាងពន្យល់ថាសម្រង់ពាក្យមួយឃ្លានេះបានដាស់តឿននាងបន្ថែមឱ្យចេះធ្វើការចែករំលែកចំណេះដឹង និងសកម្មភាពក៏ដូចជាបង្ហាញនូវសមត្ថភាពរបស់នាងផងដែរ។

យ៉ារុបានភ្ជាប់នូវភាពរីកចម្រើនរបស់នាងជាមួយនឹងអង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា ហើយនាងក៏សូមសម្តែងការថ្លែងអំណរគុណចំពោះការបង្ហាត់បង្ហាញ និងការផ្តល់ឱកាសមកដល់រូបនាងរាល់ពេលកន្លងមកនេះ។



# ដំណើររបស់ភូមិមួយ តាមរយៈជំរំអំណានតាមសហគមន៍

ដោយជាផ្នែកមួយនៃវិធីសាស្ត្រកុមាររៀន កុមារចេះ (Unlock Literacy) អង្គការទស្សនៈពិភពលោក បានកំពុងអនុវត្តជំរំអំណានក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០១៩។ កុមារជាង ២៨,០០០ នាក់បានចូលរួមក្នុងគំនិតផ្តួចផ្តើមនេះគិតមកត្រឹមខែកញ្ញា ឆ្នាំ២០២៣ ដែលក្នុងនោះមានជំរំអំណានចំនួន ៩៧០កន្លែង នៅក្នុងតំបន់គោលដៅដែលបានជ្រើសរើស។

ស្រីនីត អាយុ១១ឆ្នាំ ជាសិស្សថ្នាក់ទី៤ ជារឿយៗតែងចូលរួមក្នុងជំរំអំណានដែលមានទីតាំងនៅស្រុកសំរោង ខេត្តតាកែវ ដែលជាតំបន់គោលដៅមួយរបស់អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំកម្ពុជា។ កម្មវិធីជំរំអំណានបានបណ្តុះបណ្តាលអ្នកដឹកនាំសហគមន៍ដើម្បីជួយសម្របសម្រួលដល់ជំរំអំណាន ដោយផ្តោតលើវាក្យសព្ទ ចំណេះដឹងអក្សរ ការយល់ដឹងតាមសូរស័ព្ទ និងល្បែងស្វែងយល់ផ្សេងៗ។

ស្រីនីតលើកឡើងថា ជំរំអំណានមានសៀវភៅរឿងកម្សាន្តជាច្រើនប្រភេទ ដែលតែងធ្វើឱ្យនាងត្រឡប់ទៅខ្ចីសៀវភៅបន្ថែមទៀត។ នាងក៏អាចលេងជាមួយមិត្តភក្តិរបស់នាងក្នុងពេលជួបជុំរៀងរាល់ថ្ងៃអាទិត្យ ដែលនេះកាន់តែធ្វើឱ្យនាងសប្បាយរីករាយថែមទៀត។



កុមារីនេះបន្តថា៖ “កាលពីមុន ខ្ញុំតែងតែលេងបិតពួននៅតាមផ្លូវជុំវិញភូមិ ប៉ុន្តែឥឡូវនេះខ្ញុំបានងាកមកចំណាយពេលកាន់តែច្រើនអង្គុយអានសៀវភៅវិញ។ សៀវភៅរូបភាពខុសៗគ្នាជាច្រើនដែលខ្ញុំអាចខ្ចីពីជំរំអំណាន ហើយមានភាពងាយស្រួលក្នុងការអានជាងសៀវភៅមេរៀនរបស់ខ្ញុំ”។ ស្រីនីតបន្ថែមថា៖ “យើងក៏មាននូវសកម្មភាពសប្បាយៗនាថ្ងៃអាទិត្យផងដែរ”។

លោកយាយរបស់ស្រីនីត លោកយាយស៊ិនអាយុ៧៥ឆ្នាំ ក៏បានពន្យល់ថា ទម្លាប់របស់ស្រីនីតបានផ្លាស់ប្តូរដោយសារតែការអាន ដែលជាលទ្ធផលចេញពីគម្រោងជំរំអំណាន។ លោកយាយបានប្រាប់ថា៖ “ខ្ញុំតែងបារម្ភពីចៅស្រីនីត ព្រោះនាងតែងតែទៅលេង ហើយរត់ជុំវិញនៅខាងក្រៅ បើទោះជានៅក្រោមពន្លឺថ្ងៃដ៏ក្តៅយ៉ាងណាក៏ដោយ ខ្ញុំតែងហៅនាងឱ្យត្រឡប់មកផ្ទះវិញ”។

លោកយាយក៏បន្តថា៖ “ខ្ញុំមិនអាចអានឱ្យចៅស្រីរបស់ខ្ញុំបានទេ ដោយសារតែខ្ញុំមិនចេះអក្សរ ប៉ុន្តែចៅស្រីខ្ញុំអាចអានបានហើយ ហើយនេះធ្វើឱ្យខ្ញុំសប្បាយចិត្តណាស់”។

“ខ្ញុំបានឃើញឪពុកម្តាយជាច្រើនមកផ្តោតលើការសិក្សារបស់កូនៗ និងខិតខំប្រឹងប្រែងបន្ថែមក្នុងការលើកទឹកចិត្តការអានជាមួយកូនៗរបស់គេនៅផ្ទះ។ ថ្មីៗនេះ ខ្ញុំបានទៅចូលរួមជំរំអំណាន ហើយឃើញកម្មវិធីធ្វើបានល្អណាស់”។

កង ម៉ន អាយុ៥៧ឆ្នាំជាមេភូមិក៏បានចែករំលែកថាគាត់បានកត់សម្គាល់នូវការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថដ៏ប្រសើរនៅក្នុងសហគមន៍ទាក់ទងនិងការអប់រំ និងការអានបន្ទាប់ពីមានការចូលរួមពីជំរំអំណាន។



# ដំណើរផ្លាស់ប្តូរនៃជីវិតរបស់ម៉ាណៃ តាមរយៈកម្មវិធីទំនុកបម្រុងកុមារ

ម៉ាណៃអាយុ ១៧ឆ្នាំ បានផ្លាស់ប្តូរជីវិត និងអនាគតសហគមន៍របស់នាង នៅឃុំកំពង់ស្វាយ ខេត្តកំពង់ធំ ប្រទេសកម្ពុជា។ រឿងរ៉ាវរបស់នាងបានបង្ហាញពីភាពក្លាហាន ជំនឿជាក់លើខ្លួនឯង និងភាពធន់ដែលនាងបានកសាង ខណៈពេលដែលបានចូលរួមជាមួយអង្គការទស្សនៈពិភពលោកនៅក្នុងគម្រោងអភិវឌ្ឍសហគមន៍។

ម៉ាណៃត្រូវបានចុះឈ្មោះជាកុមារទំនុកបម្រុងកាលពីឆ្នាំ ២០១២ ជាមួយអង្គការទស្សនៈពិភពលោក។ ចំណង់ចំណូលចិត្ត និងការប្តេជ្ញាចិត្តរបស់នាងបានធ្វើឱ្យនាងក្លាយជាអ្នកដឹកនាំយុវជនសម្រាប់ការផ្លាស់ប្តូរ សមាជិកក្រុមការត្រួតពិនិត្យលើស្ថានភាពកុមារដែលដឹកនាំដោយសហគមន៍ (CLCM) និងអ្នកសម្របសម្រួលជំរំអំណាន។ គោលបំណងរបស់នាង គឺដើម្បីជួយដល់កុមារក្នុងសហគមន៍របស់នាងឱ្យអភិវឌ្ឍជំនាញអក្ខរកម្ម និងបណ្តុះនូវក្តីស្រឡាញ់សម្រាប់ការអាន។



ម៉ាណៃបានបញ្ជាក់ថា៖ “ខ្ញុំបានសម្រេចចិត្តបន្តការស្ម័គ្រចិត្តជាមួយគម្រោងរបស់អង្គការទស្សនៈពិភពលោក ដោយប្រើធនធានរបស់ខ្ញុំមកជួយសហគមន៍ខ្ញុំឱ្យបានរីកចម្រើន ហើយខ្ញុំនឹងនៅជាប់ដល់ទីបញ្ចប់ដរាបណាអង្គការនៅតែបន្តសកម្មភាពក្នុងភូមិរបស់ខ្ញុំ”។

យុវតីរូបនេះ ចំណាយពេលចុងសប្តាហ៍របស់នាងមកបង្រៀនកុមារនៅជំរំអំណាន ដែលជាលទ្ធផលបានធ្វើឱ្យនាងមានក្តីសុបិនចង់ក្លាយជាគ្រូបង្រៀននាពេលអនាគត។ ម៉ាណៃបានប្រាប់ថា៖ “ខ្ញុំធ្លាប់សង្កេតមើលឃើញគ្រូរបស់ខ្ញុំបង្រៀនកូនសិស្ស កាលនោះខ្ញុំមានអារម្មណ៍តឹងចិត្តជំនួសគាត់ជាខ្លាំង។ ប៉ុន្តែបន្ទាប់ពីខ្ញុំទទួលបានបទពិសោធន៍បង្រៀនដោយផ្ទាល់ ការយល់ឃើញរបស់ខ្ញុំត្រូវបានផ្លាស់ប្តូរទាំងស្រុង។ ឥឡូវនេះ ខ្ញុំមើលឃើញពីតម្លៃ និងបំណងប្រាថ្នាដ៏សំខាន់ក្នុងការក្លាយជាគ្រូបង្រៀនពេលខ្ញុំធំឡើង”។

នាងបានបន្ត៖ "ខ្ញុំគិតថាសហគមន៍របស់ខ្ញុំមានភាពប្រសើរឡើងច្រើន ទាក់ទងនឹងអំពើហិង្សាលើកុមារ។ ជាធម្មតាពេលឪពុកម្ដាយឈ្លោះគ្នា ពួកគេអាចប្រើអំពើហិង្សាលើកូនៗ ឬពេលខ្លះផឹកគ្រឿងស្រវឹង ហើយបំពានគ្នាទៅវិញទៅមក ប៉ុន្តែឥឡូវនេះមានការផ្លាស់ប្ដូរច្រើនណាស់នៅភូមិយើង ពួកគាត់បានយល់ដឹងច្រើនជាងមុន ទាក់ទងនឹងផលប៉ះពាល់នៃអំពើហិង្សា"។

ការជឿជាក់ទៅលើសក្ដានុពលរបស់នាងតាមរយៈអ្នកឧបត្ថម្ភ បានធ្វើឱ្យនាងមាននូវក្ដីសង្ឃឹម និងរំលឹកនាងថានាងមិននៅម្នាក់ឯងក្នុងដំណើរជីវិតនេះទេ។

ម៉ាណៃ សូមថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភរបស់នាងសម្រាប់រាល់សេចក្ដីសប្បុរសការគាំទ្រនិងការលើកទឹកចិត្តជាបន្តបន្ទាប់។

"ខ្ញុំមិនសូវចាំអ្នកឧបត្ថម្ភរបស់ខ្ញុំច្រើននោះទេ ព្រោះពួកគាត់មិនបានសរសេរសារមកខ្ញុំមួយរយៈហើយ។ តែរឿងមួយដែលខ្ញុំចងចាំបំផុតនោះគឺពាក្យលើកទឹកចិត្តរបស់ពួកគាត់។ មានពេលមួយ ពួកគាត់បានសរសេរមកខ្ញុំថា៖ "ត្រូវខំប្រឹងរៀនដើម្បីអនាគតរបស់អ្នក" នោះហើយជាអ្វីដែលខ្ញុំចងចាំបំផុត។ ខ្ញុំមានអារម្មណ៍ថាទទួលបានក្ដីស្រឡាញ់ដែលមិនគួរឱ្យជឿ ពេលខ្លះធ្វើឱ្យខ្ញុំញញឹម។ ខ្ញុំចាំបាច់ត្រូវបន្តខិតខំដើម្បីជួយខ្លួនឯង និងសម្រេចបាននូវគោលបំណងរបស់ពួកគាត់។"



## ▶ លំហូរនៃក្ដីសង្ឃឹម៖ ខ្សែជីវិតនៃទឹកស្អាតនៅភូមិបង្កួន

បង្កួន ជាភូមិមួយស្ថិតក្នុងឃុំរៀបរយ ស្រុករវៀង ខេត្តព្រះវិហារ។ ភូមិនេះមានចំងាយប្រហែល ១៨០គីឡូម៉ែត ពីទីរួមខេត្តព្រះវិហារ។ ប្រជាជននៅទីនោះភាគច្រើនខ្វះទឹកស្អាតសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ ដោយពួកគេត្រូវដើរចម្ងាយពី ៥០០ម៉ែត្រ ទៅ ៥គីឡូម៉ែត្រ ដើម្បីយកទឹកតាមស្រះតូចៗ និងអូរ។ អ្នករស់នៅក្នុងភូមិបង្កួនជាពិសេសកុមារងាយនឹងកើតនូវជំងឺផ្លូវដង្ហើម រាករូស និងបញ្ហាផ្សេងៗ ដែលទាក់ទងនឹងទឹក និងការបញ្ចេញចោល ដោយសារកង្វះអនាម័យ និងការអនុវត្តអនាម័យមិនបានត្រឹមត្រូវ។

វីរៈ ជាកុមារាមានអាយុ១៤ឆ្នាំ និងជាកូនប្រុសច្បងក្នុងគ្រួសារដែលមានសមាជិក៦នាក់បាននិយាយប្រាប់ថា៖ "ពេលខ្លះខ្ញុំមិនអាចទៅសាលារៀនទាន់ពេល ដោយសារខ្ញុំត្រូវទៅដងយកទឹកឱ្យគ្រួសាររបស់ខ្ញុំ។ ឥឡូវនេះខ្ញុំមិនចាំបាច់ព្រួយបារម្ភទៀតទេ ព្រោះមានបំពង់ទឹកភ្ជាប់នឹងពាងរបស់ខ្ញុំហើយ"។

មុននឹងមានប្រព័ន្ធតំណភ្ជាប់ទឹកស្អាត គ្រួសាររបស់វីរៈបានប្រើប្រាស់ទឹកដែលយកពីអណ្ដូងតាមភូមិ និងស្រះតូចៗ ជាមួយគ្រួសារផ្សេងៗទៀត។



បន្ទាប់ពីបញ្ចប់នូវការវាយតម្លៃ មូលនិធិទំនុកបម្រុងសហគមន៍ ត្រូវបានផ្ដល់ដើម្បីសាងសង់នូវប្រព័ន្ធតំណភ្ជាប់ទឹកស្អាត ដែលមានទំហំមធ្យមក្នុងឃុំចំនួន ២ (ឃុំរៀបរយ និងឃុំរហ័ស) នៅស្រុករវៀងដើម្បីគាំទ្រសហគមន៍នៅក្នុងការទទួលបានទឹកស្អាតប្រើប្រាស់ និងការពារកុមារពីការឆ្លងមេរោគ និងជំងឺផ្សេងៗ។ ប្រព័ន្ធតំណភ្ជាប់ទឹកស្អាតត្រូវបានសាងសង់ឡើងដោយប្រើប្រាស់សម្ភារដែលមានភាពធន់ និងគុណភាពខ្ពស់ ដើម្បីធានាបាននូវភាពជាប់បានយូរនិងភាពជឿជាក់។

នៅខែសីហា ឆ្នាំ២០២៣ ប្រព័ន្ធតំណភ្ជាប់ទឹកស្អាតដែលមានទំហំមធ្យម ត្រូវបានបើកឱ្យប្រើប្រាស់ដើម្បីបម្រើដល់កុមារ និងប្រជាពលរដ្ឋនៅក្នុងឃុំទាំង២ ដែលផ្តល់ផលប្រយោជន៍ដល់ភូមិចំនួន៣ រួមមាន ភូមិបង្កុនដែលអនុញ្ញាតឱ្យអ្នកភូមិមានលទ្ធភាពទទួលបានទឹកស្អាត និងមានសុវត្ថិភាពប្រើប្រាស់ជាប្រចាំថ្ងៃ។ ប្រព័ន្ធតំណភ្ជាប់ទឹកស្អាតដែលមានទំហំមធ្យម មិនត្រឹមតែរួមចំណែកជួយបម្រើតម្រូវការប្រចាំថ្ងៃរបស់អ្នកភូមិ និងគ្រួសាររបស់វីរៈប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើតប្រាក់ចំណូលសម្រាប់គ្រួសារផងដែរ ដោយពួកគាត់បានប្រើប្រាស់ទឹកសម្រាប់កសិដ្ឋានរបស់គាត់ក្នុងការដាំបន្លែ និងចិញ្ចឹមសត្វ។

ជាមួយនឹងបំពង់តភ្ជាប់ទៅតាមផ្ទះ ពួកគាត់អាចសន្សំពេលវេលា និងកែលម្អសុខភាពនិងអនាម័យរបស់ពួកគាត់ជាពិសេសគឺកុមារៗដូចវីរៈ អាចទៅសាលារៀនបានដោយលែងបារម្ភពីហានិភ័យណាមួយដែលពួកគេអាចប្រឈម ពេលទៅដងយកទឹកដែលស្ថិតនៅឆ្ងាយពីផ្ទះ។



ក្រោមការគ្រប់គ្រងរបស់គណៈកម្មាការគ្រប់គ្រងទឹក ប្រព័ន្ធទឹកស្អាតបានផ្តល់នូវទឹកស្អាត និងសុវត្ថិភាពទៅដល់ប្រជាជនសរុបចំនួន ២៩១នាក់ក្នុងចំណោមប្រជាជនសរុបនៃភូមិបង្កុន រួមបញ្ចូលទាំងកុមារដែលងាយរងគ្រោះបំផុតចំនួន ១២៣នាក់ (ក្នុងនោះមានកុមារីចំនួន ៧៨នាក់) ដែលរស់នៅក្នុងភូមិបង្កុន។

World Vision

## សេចក្តីថ្លែងការណ៍បេសកកម្ម

អង្គការទស្សនៈពិភពលោក គឺជាដៃគូអន្តរជាតិមួយនៃគ្រិស្តបរិស័ទ ដែលមានបេសកកម្មដើរតាមព្រះអម្ចាស់ ព្រះយេស៊ូគ្រិស្ត ជាព្រះសង្គ្រោះ ដោយធ្វើការជាមួយជនក្រីក្រ និងជនដែលរងការគាបសង្កត់ ដើម្បីបង្កើតឱ្យមានការផ្លាស់ប្រែដល់មនុស្សជាតិ ស្វែងរកភាពយុត្តិធម៌ និងធ្វើទីបន្ទាល់ពីដំណឹងល្អនៃនគរព្រះ។

## ទំនាក់ទំនង


ប្រអប់សំបុត្រលេខ 479 ភ្នំពេញ កម្ពុជា

Phone (+855) 23 216 052
Fax (+855) 23 216 220

contact_cambodia@wvi.org
www.wvi.org/cambodia

facebook.com/ WorldVisionCambodia

@WorldVisionKH

youtube.com/wvcambodia